ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ផែនការសកម្មភាពសម្រាប់អនុវត្ត
# គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា
# ឆ្នាំ២០១៥-២០២៥



ខែសីហា ឆ្នាំ២០១៥

**ឧបត្ថម្ភបោះពុម្ពដោយ៖**

កម្មវិធី ៖ "ជំរុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាព និងបរិយាប័ន្ន : អនុវិស័យជលផល និងផលិតកម្មសត្វ"

កម្មវិធីនេះគាំទ្រថវិកាដោយសហភាពអឺរ៉ុប

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវ **"គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥"** នៅដើមខែមិថុនា ឆ្នាំ២០១៥ កន្លងទៅនេះ ដើម្បីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា ដែលនឹងរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រីកការប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព។

ឯកសាគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជានេះបានកំណត់ច្បាស់អំពីស្ថាប័ននាំមុខ និងស្ថាប័នទទួលខុសត្រូវ និងបានកំណត់ច្បាស់នូវចំណុចវិធានការគោលនយោបាយ និងផែនការសកម្មភាពសំខាន់ៗពាក់ព័ន្ធផលិតកម្មកសិ-ឧស្សាហកម្ម រួមមាន (ទី១)-ការពិនិត្យលទ្ធភាពបង្កើតនូវតំបន់កែច្នៃកសិផល និងការផ្តល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុនទាំងឡាយណាដែលបោះទីតាំងនៅក្នុងតំបន់ទាំងនោះ (ទី២)-បង្កើតមូលនិធិសម្រាប់ជំរុញការអភិវឌ្ឍផលិតផលបច្ចេកទេសកែច្នៃកសិផល និងការអភិវឌ្ឍបច្ចេកទេសដោយភ្ជាប់ទៅនឹងសក្តានុពលនាំចេញ (ទី៣)-រៀបចំសម្រួលយន្តការដល់ការនាំចេញកសិផលកែច្នៃ ដោយដោះស្រាយបញ្ហាឡូជីស្ទិក លុបបំបាត់កម្រៃក្រៅផ្លូវការ និងកែលម្អការសម្រួលពាណិជ្ជកម្ម (ទី៤)-កំណត់នូវមុខងារទំនិញអាទិភាព ដែលមានសក្តានុពលកែច្នៃសម្រាប់នាំចេញ និងរៀបចំផែនការសកម្មភាពជាក់លាក់គាំទ្រការអភិវឌ្ឍវិស័យនេះ។

ចំណុចគន្លឹះដែលត្រូវយកចិត្តទុកដាក់ក្នុងការជំរុញការអភិវឌ្ឍកសិ-ឧស្សាហកម្ម ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយដែលបានដាក់ឱ្យអនុវត្តនេះ គឺការតម្រង់ទិសការអភិវឌ្ឍតំបន់កែច្នៃកសិផល តំបន់កែច្នៃនិងផលិតផលសង្ហារឹម តំបន់កែច្នៃផលិតសម្ភារអំពីកៅស៊ូ តំបន់កែច្នៃផលិតម្ហូបអាហារពីផលិតផលដំណាំ បសុសត្វ និងជលផល និងការអភិវឌ្ឍសួនកសិ-ឧស្សាហកម្មសម្រាប់គោលដៅនៃការប្រមូលផ្តុំកសិផល ដែលមានសក្តានុពលសម្រាប់កែច្នៃប្រើប្រាស់ក្នុងស្រុកនិងនាំចេញ។យន្តការគន្លឹះដែលត្រូវយកចិត្តទុកដាក់ជំរុញការអភិវឌ្ឍកសិឧស្សាហកម្មនោះគឺ ការសម្របសម្រួល និងការលើកទឹកចិត្តវិស័យឯកជន ក្នុងការអភិវឌ្ឍបច្ចេកទេសកែច្នៃកសិផល ស្របតាមស្តង់ដារផលិតផលអាស៊ាន និងតម្រូវការស្តង់ដារទីផ្សារអន្តរជាតិ។ ការផ្សារភ្ជាប់រវាងក្រុមអ្នកផលិតជាមួយអ្នកប្រមូលទិញតាមយន្តការ "*ផលិតកម្មកសិកម្មតាមកិច្ចសន្យា*" ដើម្បីធានាការផ្គត់ផ្គង់កសិផលប្រកបដោយនិរន្តរភាព គឺជាចំណុចយុទ្ធសាស្ត្រដ៏សំខាន់ផងដែរ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានប្រមូលផ្តុំនូវសក្តានុពលក្នុងការរៀបចំផែនការសកម្មភាពដើម្បីចូលរួមចំណែកជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឱ្យមានប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់ និងមានជំនឿជឿជាក់ថា ផែនការសកម្មភាពដែលបានរៀបចំនេះ ពិតជានឹងអាចអនុវត្តទៅបានប្រកបដោយជោគជ័យ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០១៥

**រដ្ឋមន្ត្រី**

# មាតិកា


| | ទំព័រ |
|---|---|
| **ផ្នែកទី ១:គោលនយោបាយអភិវឌ្ឍន៍វិស័យកសិ-ឧស្សាហកម្មកម្ពុជា......................** | ១ |
| I- **សេចក្ដីផ្ដើម**.................................................................................................. | ១ |
| II- **ស្ថានភាពវិវឌ្ឍរីកចម្រើននៃវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម...................** | ២ |
| ក. សមិទ្ធផលនៃវិស័យកសិកម្ម.............................................................................. | ២ |
| ខ. ស្ថានភាពបច្ចុប្បន្ននៃវិស័យកសិ-ឧស្សាហកម្ម......................................................... | ៣ |
| គ. បញ្ហាប្រឈមនិងកាលានុវត្តភាព........................................................................... | ៥ |
| III- **ចក្ខុវិស័យនិងយុទ្ធសាស្ត្រក្នុងការជំរុញការអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា.............** | ៦ |
| ក. ចក្ខុវិស័យនិងទិសដៅយុទ្ធសាស្ត្រ........................................................................ | ៦ |
| ខ. អភិក្រមដើម្បីសម្រេចបានទិសដៅគោលនយោបាយ.................................................... | ៧ |
| គ. គោលនយោបាយនិងស្ថាប័នជំរុញការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម............................... | ៧ |
| **ផ្នែកទី ២:ផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យ ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥......................................................** | ១០ |
| IV- **ផែនការសកម្មភាព**......................................................................................... | ១០ |
| ១.១វិធានការជំរុញការទាក់ទាញវិនិយោគ..................................................................... | ១០ |
| ១.២វិធានការពង្រីកនិងទំនើបកម្មសហគ្រាសកសិកម្មធុនតូចនិងមធ្យម................................. | ១០ |
| ១.៣វិធានការពាក់ពន្ធ័នឹងការកែលម្អបរិស្ថាននិយ័តកម្ម..................................................... | ១៣ |
| ១.៤វិធានការសម្របសម្រួលគោលនយោបាយ.................................................................. | ១៤ |
| V- **គម្រោងថវិកាសម្រាប់អនុវត្តសកម្មភាព**.......................................................... | ១៤ |
| VI- **យន្តការអនុវត្ត ការតាមដាននិងវាយតម្លៃ**........................................................ | ១៥ |
| ១- យន្តការអនុវត្ត................................................................................................. | ១៥ |
| ២- ការតាមដាននិងវាយតម្លៃ..................................................................................... | ១៦ |
| VII- **សេចក្ដីសន្និដ្ឋាន**............................................................................................ | ១៦ |

# ផែនការសកម្មភាព
# សម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា
# ឆ្នាំ២០១៥-២០២៥

## ផ្នែកទី ១: គោលនយោបាយអភិវឌ្ឍន៍វិស័យកសិ-ឧស្សាហកម្មកម្ពុជា

### I- សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាតាមរយៈយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣បានកំណត់ការលើកស្ទួយវិស័យកសិកម្មជាចតុកោណទី១ក្នុងចំណោមចតុកោណយុទ្ធសាស្រ្តទាំងបួនដែលមានតួនាទីសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច ធានាសមធម៌ធានាសន្តិសុខស្បៀងនិងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ។ ក្នុងការលើកស្ទួយវិស័យកសិកម្មរាជរដ្ឋាភិបាលនឹងបន្តជំរុញការធ្វើពាណិជ្ជូបនីយកម្មនិងការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្មដែលនឹងជួយបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្មក៏ដូចជាជួយបង្កើនចំណូលដល់ប្រជាកសិករ។ ការដាក់ចេញនិងជំរុញអនុវត្តគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករនិងយុទ្ធសាស្រ្តសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជាឆ្នាំ២០១១-២០២០ បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រេចបាននូវការលើកស្ទួយវិស័យកសិកម្ម។

លើសពីនេះទៀតរាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកផលិតកម្មកសិ-ឧស្សាហកម្មដែលបម្រើឲ្យការនាំចេញនិងទីផ្សារក្នុងស្រុកគឺជាវិស័យអាទិភាពមួយក្នុងវិស័យអាទិភាពទាំង៥ដូចដែលបានកំណត់នៅក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥។ តាមរយៈការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មនេះរាជរដ្ឋាភិបាលនឹងជំរុញការនាំចេញទំនិញកែច្នៃកសិកម្មឱ្យបាន១២% នៃបរិមាណនាំចេញសរុបនៅត្រឹមឆ្នាំ២០២៥។

ដើម្បីសម្រេចបានគោលបំណងខាងលើនេះរាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការគោលនយោបាយមួយចំនួនដូចជា (ក) ការពិនិត្យលទ្ធភាពបង្កើតនូវតំបន់កែច្នៃកសិផលនិងការផ្តល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុនទាំងឡាយណាដែលបោះទីតាំងនៅក្នុងតំបន់ទាំងនោះ (ខ) បង្កើតមូលនិធិសម្រាប់ជំរុញការអភិវឌ្ឍផលិតផលបច្ចេកទេសកែច្នៃកសិផលនិងការអភិវឌ្ឍបច្ចេកទេសដោយភ្ជាប់ទៅនឹងសក្តានុពលនាំចេញ (គ) រៀបចំសម្រួលយន្តការដល់ការនាំចេញកសិផលកែច្នៃដោយដោះស្រាយបញ្ហាឡូជីស្ទិកលុបបំបាត់កម្រៃក្រៅផ្លូវការនិងកែលម្អការសម្រួលពាណិជ្ជកម្ម (ឃ) កំណត់នូវមុខងារទំនិញអាទិភាពដែលមានសក្តានុពលកែច្នៃសម្រាប់នាំចេញនិងរៀបចំផែនការសកម្មភាពជាក់លាក់គាំទ្រការអភិវឌ្ឍវិស័យនេះ។

## II- ស្ថានភាពវិវឌ្ឍរីកចម្រើននៃវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម

### ក. សមិទ្ធផលនៃវិស័យកសិកម្ម

#### (១). ផលិតកម្មដំណាំស្រូវ

ផលិតកម្មដំណាំស្រូវក្នុងឆ្នាំ២០១៤-២០១៥អនុវត្តបានលើផ្ទៃដីចំនួន៣.០៥៥.៥០៧ហិកតា។ផ្ទៃដីអាចប្រមូលផលបានមានចំនួនប្រមាណ៣.០២៨.៨៣៦ហិកតានិងបរិមាណផលសរុបទទួលបានចំនួន៩.៣២៤.៤១៦តោន។ ទិន្នផលមធ្យមប្រចាំឆ្នាំ២០១៤ទទួលបានមានចំនួន៣,០៧៩តោនក្នុងមួយហិកតា។អតិរេកស្បៀងគិតជាអង្ករមានចំនួនប្រមាណ៣.០១៣.៧៨៣តោនឬស្មើនឹង៤.៧០៩.០៣៦តោនស្រូវ។

#### (២). ផលិតកម្មដំណាំកៅស៊ូ

ក្នុងឆ្នាំ២០១៤ផ្ទៃដីដំណាំកៅស៊ូដាំដុះមានចំនួន៣៥៧.៨០៩ហិកតាកើនឡើងប្រមាណ៩,២% បើប្រៀបធៀបឆ្នាំ២០១៣ (៣២៨.៨០០ហិកតា)។ផ្ទៃដីចៀរជ័រមានចំនួន៩០.៥៤៥ហិកតាកើនឡើងប្រមាណ១៥,៤% បើធៀបនឹងឆ្នាំ២០១៣ (៧៨.៤៩៣ហិកតា)។ បរិមាណផលិតផលកៅស៊ូសម្រេចបានប្រមាណ៩៧.០៥៤តោនកើនឡើងប្រមាណ១៣,៨% បើធៀបនឹងឆ្នាំ២០១៣ (៨៥.៣០០តោន)។

#### (៣). ដំណាំរួមផ្សំនិងឧស្សាហកម្ម

ផ្ទៃដីផលិតកម្មដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន៩៥៣.៥៩៧ហិកតាលើសឆ្នាំមុនចំនួន១២.៥៦៩ហិកតានិងទទួលបានបរិមាណផលសរុបចំនួន១៤.៧២៧.២៦២តោនលើសឆ្នាំ២០១៣ចំនួន៤.១៩០.៥២០តោន។

#### (៤). ការជំរុញការនាំចេញផលិតផលកសិកម្ម

ក្នុងឆ្នាំ២០១៤ការជំរុញការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារតំបន់និងពិភពលោកសម្រេចបានចំនួន៤៧មុខមានបរិមាណសរុបចំនួន៣.៤៤៥.២៦៦,៥៦តោន។

- **ការនាំចេញអង្ករ**÷កើនឡើងតិចតួចគឺកើនពី៣៧៨.៨៥៦តោនក្នុងឆ្នាំ២០១៣ដល់៣៨៧.០៦១តោនក្នុងឆ្នាំ២០១៤ឬស្មើនឹង២,២% ធៀបនឹងឆ្នាំ២០១៣ដែលក្នុងនោះអង្ករសគ្រប់ប្រភេទមានចំនួន១៥៧.៤១៧តោនអង្ករក្រអូបគ្រប់ប្រភេទចំនួន២១០.៥៩៤តោននិងអង្ករចំហុយចំនួន១៩.០៥០តោន។ ក្រុមហ៊ុននាំអង្ករចេញសរុបមានចំនួន៨៦ក្រុមហ៊ុន។
- **ការនាំចេញកៅស៊ូ**÷សម្រេចបានចំនួន១០០.១៥១តោនបើធៀបនឹងឆ្នាំ២០១៣មានចំនួន៨៦.០៥២តោនគឺផលិតផលកៅស៊ូនាំចេញកើនឡើង១៦,៣៨%។តម្លៃកៅស៊ូឆ្នាំ២០១៤គិតជាមធ្យមស្មើនឹង១.៥៣៩ដុល្លារអាមេរិកក្នុងមួយតោនបើធៀបនឹងឆ្នាំ២០១៣ដែលតម្លៃកៅស៊ូមធ្យម២.២០១ដុល្លារអាមេរិកក្នុងមួយតោនគឺធ្លាក់ចុះ៦៦២ដុល្លារអាមេរិកក្នុងមួយតោនស្មើនឹង៣០%។នៅឆ្នាំ២០១៤រោងចក្រសិប្បកម្មកែច្នៃផលិតផលកៅស៊ូសរុបមានចំនួន៩៨កន្លែងគឺកើនឡើងចំនួន ៤០% បើធៀបទៅនឹងឆ្នាំ២០១៣ដែលមានតែ៧០កន្លែងប៉ុណ្ណោះក្នុងនោះមានរោងចក្រកែច្នៃកៅស៊ូដុំ (TSR) ចំនួន៣៤កន្លែងរោងចក្រសិប្បកម្មកែច្នៃកៅស៊ូសន្លឹក (RSS)ចំនួន៦០កន្លែងនិងរោងចក្រកែច្នៃឈើកៅស៊ូចំនួន៤កន្លែង។

- **ការនាំចេញផលិតផលដំឡូងមី÷** ការនាំចេញចំណិតដំឡូងមីក្រៀមសរុបមានចំនួន៩៦១.២៧៥តោនដំឡូងមីស្រស់៣១៧.៦១៣តោនម្សៅដំឡូងមី៧.០៣៥តោន។មកទល់ពេលនេះមានក្រុមហ៊ុនចំនួន៥៧ក្រុមហ៊ុនត្រូវបានពិនិត្យវាយតម្លៃនិងចុះបញ្ជីទទួលស្គាល់ជាក្រុមហ៊ុននាំចេញចំណិតដំឡូងមីក្រៀមទៅកាន់ទីផ្សារប្រទេសចិន។
- **ការនាំចេញផលិតផលកសិកម្មផ្សេងៗទៀត÷** ការនាំចេញសណ្តែកសៀងមានចំនួន១៥.៣៣៣តោនដូងប្រេង ២.៧៣៨តោនពោត៩០.៦៨១តោននិងគ្រាប់ស្វាយចន្ទី៥១.២១៦តោន។
- **ការនាំចេញសត្វរស់ និងផលិតផលមានដើមកំណើតពីសត្វ÷** ការនាំចេញគោក្របីមានចំនួន ១២.១៦០ក្បាល ជ្រូកមេបាពូជចំនួន ២.០១៧ក្បាល ជ្រូកពូជកូនចំនួន ៥០.៤០០ក្បាល ស្វាក្តាមចំនួន ៤.៥៣០ក្បាល ស្បែកគោក្របីចំនួន ១.៦២០តោន ចំណីផ្អែចំនួន ១.១៨០តោន ។
- **ការនាំចេញឈើកែច្នៃ÷** ការនាំចេញឈើកែច្នៃគ្រប់ប្រភេទមានចំនួន ៧៥.២៩០ម៉ែត្រត្រីគុណ ឈើអាកាស្យាកាត់កង់ៗចំនួន ៥០០ស្ទែរ ចំណិតឈើដាំចំនួន ៣.៩៣០តោន និងធ្យូងអាកាស្យាចំនួន៣២តោន។

ទីផ្សារផលិតផលកសិកម្មកម្ពុជានឹងត្រូវបានពង្រីកបន្ថែមទៀតក្នុងពេលខាងមុខក្រោយពេលដែលពិធីសារចំនួន៣ទៀតត្រូវបានអនុវត្តពេញលេញជាមួយសាធារណរដ្ឋប្រជាមានិតចិនរួមមាន (១) ពិធីសារស្តីពីការនាំចេញផលិតផលពោតកម្ពុជាទៅកាន់ប្រទេសចិន (២) ពិធីសារស្តីពីការនាំចេញផ្លែចេកស្វាយនិងសណ្តែកសៀងកម្ពុជាទៅកាន់ប្រទេសចិននិង (៣) ពិធីសារស្តីពីការនាំចេញអង្ករទៅប្រទេសចិនដែលឯកសារពាក់ព័ន្ធទាំង៣នេះត្រូវបានចុះហត្ថលេខារួចហើយរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាមួយនឹងអគ្គរដ្ឋបាលត្រួតពិនិត្យគុណភាពអធិការកិច្ចនិងចត្តាឡីស័កនៃសាធារណរដ្ឋប្រជាមានិតចិនក្នុងកំឡុងពេលកិច្ចប្រជុំរដ្ឋមន្រ្តីកសិកម្មនិងព្រៃឈើអាស៊ាននៅប្រទេសមីយ៉ាន់ម៉ាក្នុងឆ្នាំ២០១៤។ បន្ថែមលើនេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក៏បាននិងកំពុងរៀបចំពិធីសារស្តីពីការនាំចេញផ្លែស្វាយទៅកាន់សាធារណរដ្ឋកូរ៉េផងដែរ។

## ខ. ស្ថានភាពបច្ចុប្បន្ននៃវិស័យកសិ-ឧស្សាហកម្ម

ទោះបីកម្ពុជាបានសម្រេចនូវកំណើនសេដ្ឋកិច្ចជាលំដាប់និងមានការវិវត្តផ្នែកឧស្សាហកម្មឈានឡើងមួយកម្រិតក៏ដោយក៏វិស័យកសិ- ឧស្សាហកម្មនៅមិនទាន់មានការអភិវឌ្ឍប្រកបដោយថាមវន្តនៅឡើយ។កត្តាទាំងនេះមានដូចខាងក្រោម÷

- តម្លៃបន្ថែមនៅមានកម្រិត÷តម្លៃបន្ថែមនៃសមាសធាតុចម្បងៗក្នុងកសិ- ឧស្សាហកម្មរួមចំណែកត្រឹមតែ ៣,៩% នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស)។ លើសពីនេះវិស័យកសិ- ឧស្សាហកម្មមានកំណើនយឺត (ដោយអត្រាកំណើនជាមធ្យមប្រចាំឆ្នាំអំឡុងឆ្នាំ២០០២និង២០១២គឺមានតែ៣,២%)។
- ការវិនិយោគនៅមានកម្រិត÷នៅចន្លោះឆ្នាំ១៩៩៤ដល់ត្រីមាសទីមួយនៃឆ្នាំ២០១៥គម្រោងវិនិយោគក្នុងវិស័យកសិកម្មនិងកសិ- ឧស្សាហកម្មមានទំហំទឹកប្រាក់សរុបចំនួនប្រមាណ៤,៨ពាន់លានដុល្លារអាមេរិកដែលស្មើនឹង៩,៥១%នៃទំហំទឹកប្រាក់សរុបនៃគម្រោងវិនិយោគនានាដែលត្រូវបានអនុម័ត។ក្នុងអំឡុងពេលដូចគ្នានេះគម្រោងវិនិយោគលើឧស្សាហកម្មកែច្នៃចំណីអាហារមានចំនួនប្រមាណ៨៤៥លានដុល្លារអាមេរិកឬស្មើនឹង ១,៦៥%នៃទំហំទឹកប្រាក់វិនិយោគសរុប។

- សមត្ថភាពនាំចេញនៅទន់ខ្សោយ÷ទោះបីជាចំនួននៃការនាំចេញផលិតផលកសិកម្មនិងផលិតផលកែច្នៃកសិកម្មបានកើនឡើងពី២០៥លានដុល្លារអាមេរិកនៅឆ្នាំ២០១០ដល់៦៥២លានដុល្លារអាមេរិកនៅឆ្នាំ២០១៤ក្តីតែតួលេខនេះមានចំនួនត្រឹមតែ៥%នៃការនាំចេញសរុបប៉ុណ្ណោះ។

តារាងទី១÷បច្ចុប្បន្នភាពនៃគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលបានចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងវិស័យកសិកម្មកសិ-ឧស្សាហកម្មនិងឧស្សាហកម្មកែច្នៃចំណីអាហារពីឆ្នាំ១៩៩៤ដល់ត្រីមាសទី១ឆ្នាំ២០១៥។

| ប្រភេទគម្រោង | ស្ថានភាព | ទុនវិនិយោគ ដុល្លារអាមេរិក)) | មុខសញ្ញាអាជីវកម្ម | ទីតាំងវិនិយោគ |
|---|---|---|---|---|
| **កសិកម្ម និងកសិ-ឧស្សាហកម្ម** | មានសកម្មភាព ១៣១ គម្រោង | **៤១៩៩លាន.** | ▪ ដំណាំកសិ-ឧស្សាហកម្ម ដូចជាកៅស៊ូដូងប្រេង ស្វាយចន្ទីអំពៅដំឡូងឈើ សណ្តែកសៀងពោត ល្ហុង-ខ្ទងនិងដំណាំផ្សេងៗទៀត<br>▪ ដាំដើមអាកាស្យា ម៉ៃសាក់<br>▪ ការកែច្នៃផលិតផលកសិ-ឧស្សាហកម្ម ដូចជា ស្ករស កៅស៊ូ ដូងប្រេង ជាដើម<br>▪ ការចិញ្ចឹមសត្វ | ▪ កោះកុង មាន ៨ គម្រោង<br>▪ កំពង់ចាម មាន ៨ គម្រោង<br>▪ កំពង់ស្ពឺ មាន ១០ គម្រោង<br>▪ កំពង់ធំ មាន ១១ គម្រោង<br>▪ ក្រចេះ មាន ២៥ គម្រោង<br>▪ មណ្ឌលគីរី មាន ១៣ គម្រោង<br>▪ រតនគីរី មាន ១១ គម្រោង<br>▪ ព្រះសីហនុ មាន ១២ គម្រោង<br>▪ ស្ទឹងត្រែង មាន ១០ គម្រោង<br>▪ ឧត្តរមានជ័យ មាន ៨ គម្រោង<br>▪ ខេត្តដទៃ មាន ១៥ គម្រោង |
| | គ្មានសកម្មភាព ៤៧ គម្រោង | ៦៦១លាន | គ្មាន | គ្មាន |
| **ឧស្សាហកម្មកែច្នៃចំណីអាហារ** | មានសកម្មភាព ៦៥ គម្រោង | **៧៤៨លាន** | ▪ ការកិនស្រូវ និងពោត<br>▪ ផលិតចំណីសត្វ<br>▪ កែច្នៃគ្រឿងសមុទ្រ<br>▪ កែច្នៃមី គុណទាវ ស្ករគ្រាប់ នំ ផ្លែឈើ និងកែច្នៃម្ហូបអាហារផ្សេងៗ | ▪ ភ្នំពេញ មាន ២២ គម្រោង<br>▪ បាត់ដំបង មាន ៩ គម្រោង<br>▪ កំពង់ស្ពឺ មាន ៨ គម្រោង<br>▪ កណ្តាល មាន ៦ គម្រោង<br>▪ ព្រះសីហនុ មាន ៧ គម្រោង<br>▪ ខេត្តដទៃ មាន ១៥ គម្រោង |
| | គ្មានសកម្មភាព ៣៥ គម្រោង | ៩៧លាន | គ្មាន | គ្មាន |
| **សរុប** | **មានសកម្មភាព ១៩៨ គម្រោង** | **៤.៩៤៨លាន** | | |

<u>ប្រភព</u>÷ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)

### គ. បញ្ហាប្រឈមនិងកាលានុវត្តភាព

ភាពជោគជ័យនៃវិស័យកសិ-ឧស្សាហកម្មត្រូវបានកំណត់ដោយកត្តារួមផ្សំជាច្រើនដែលកើតចេញពីបរិស្ថានវិនិយោគនិងធុរកិច្ចដែលមានលក្ខណៈអនុគ្រោះសមត្ថភាពផ្នែកផ្គត់ផ្គង់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធនិងឡូជីស្ទិកបច្ចេកវិទ្យាមូលធនមនុស្សនិងក្របខណ្ឌគតិយុត្តផ្សេងៗ។ ប៉ុន្តែចំពោះប្រទេសកម្ពុជាយើងមានបញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលជាឧបសគ្គដល់ការអភិវឌ្ឍកសិ-ឧស្សាហកម្មរួមមាន÷

- **បញ្ហាប្រឈមផ្នែកផលិតកម្ម**÷រួមមានផលិតភាពការគ្រប់គ្រងទឹកនិងប្រព័ន្ធធារាសាស្ត្រគុណភាពនៃធាតុចូលនិងសេវាផ្នែកកសិកម្មនៅមានកម្រិតទាបនៅឡើយ។
- **បញ្ហាប្រឈមផ្នែកហេដ្ឋារចនាសម្ព័ន្ធ**÷រួមមានការដឹកជញ្ជូនសេវាឡូជីស្ទិកគយ (?) និងការផ្គត់ផ្គង់ទឹកសេវាទូរគមនាគមន៍និងអគ្គិសនី។
- **បញ្ហាផ្នែកបច្ចេកវិទ្យានិងបច្ចេកទេស**÷រួមមានលទ្ធភាពទទួលបានបច្ចេកវិទ្យាក្រោយការប្រមូលផលមូលធនមនុស្សព័ត៌មានទូរគមនាគមន៍និងបច្ចេកវិទ្យា។
- **បញ្ហាប្រឈមផ្នែកគតិយុត្ត**÷រួមមានកង្វះស្តង់ដារនិងប្រព័ន្ធគ្រប់គ្រងចំណីអាហារនិងបទប្បញ្ញត្តិទាក់ទងនឹងចំណីអាហារ។
- **បញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុនិងទីផ្សារ**÷រួមមានការពិបាកក្នុងការទទួលបានហិរញ្ញប្បទានអត្រាការប្រាក់ខ្ពស់ការដាក់ទ្រព្យធានានិងការពិបាកក្នុងការស្វែងរកទីផ្សារលក់ផលិតផល។

បើទោះបីជាវិស័យកសិ-ឧស្សាហកម្មនៅកម្ពុជាជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចបានរៀបរាប់ខាងលើក៏ដោយក៏វិស័យនេះនៅមានសក្តានុពលដ៏ធំធេងក្នុងការអភិវឌ្ឍសេដ្ឋកិច្ចដែលរួមចំណែកដល់ការបង្កើតការងារ ការបង្កើតតម្លៃបន្ថែមការជំរុញឧស្សាហូបនីយកម្មនិងលើកកម្ពស់សមត្ថភាពនាំចេញ។ កាលានុវត្តភាពទាំងនោះរួមមាន÷

- ✓ **ឧត្តមភាពប្រកួតប្រជែងផ្នែកកសិកម្ម**÷កម្ពុជាសំបូរទៅដោយវត្ថុធាតុដើមនិងមានកម្លាំងពលកម្មដែលមានថ្លៃឈ្នួលទាបប៉ុន្តែយើងមិនទាន់បានប្រើសក្តានុពលរបស់ខ្លួនឱ្យអស់ពីសមត្ថភាពនៅឡើយ។ ជាមួយនឹងគោលនយោបាយគាំទ្រសមស្របនិងកំណើននៃការវិនិយោគលើវិស័យកសិកម្មផលិតកម្មនិងសមត្ថភាពផ្គត់ផ្គង់វត្ថុធាតុដើមនិងផលិតផលពាក់កណ្តាលសម្រេចសម្រាប់ការកែច្នៃផលិតផលកសិកម្មក៏នឹងមានការកើនឡើងផងដែរ។
- ✓ **កំណើននៃការប្រើប្រាស់**÷ប្រជាជនដែលមានកម្រិតជីវភាពមធ្យមនៅកម្ពុជាកំពុងមានការកើនឡើងយ៉ាងឆាប់រហ័សបូកផ្សំនឹងកំណើននៃការអភិវឌ្ឍនគរូបនីយកម្មជាកត្តាជំរុញកំណើននៃតម្រូវការកាន់តែខ្លាំងនូវផលិតផលចំណីអាហារនិងមិនមែនចំណីអាហារ។
- ✓ **គោលនយោបាយពាណិជ្ជកម្មសមស្រប**÷គោលនយោបាយនេះផ្តោតសំខាន់លើការជំរុញផលិតផលកម្ពុជាចូលក្នុងទីផ្សារតំបន់និងអន្តរជាតិ។ កម្ពុជាជាសមាជិកនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) អាស៊ានបូកមួយនិងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP)។ លើសពីនេះកម្ពុជាក៏ទទួលបានអត្ថប្រយោជន៍ពីកម្មវិធីប្រព័ន្ធអនុគ្រោះពន្ធ (GSP) នៃបណ្តាប្រទេសមួយចំនួនដូចជាសហភាពអឺរ៉ុបកាណាដានិងជប៉ុន។ឱកាសនៃការចូលរួមក្នុងទីផ្សារធំៗរបស់ពិភពលោកដែលមានភាពអនុគ្រោះ

គឺជាការលើកទឹកចិត្តដល់សហគ្រាសបម្រើការនាំចេញឱ្យធ្វើការវិនិយោគក្នុងវិស័យកែច្នៃផលិតផលកសិកម្ម។

- ✓ **គោលនយោបាយត្រឹមត្រូវរបស់រាជរដ្ឋាភិបាល**÷រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយដ៏ត្រឹមត្រូវជាមូលដ្ឋានសម្រាប់ដោះស្រាយនូវបញ្ហាសំខាន់ៗដូចជាការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគនិងធុរកិច្ចហេដ្ឋារចនាសម្ព័ន្ធទន់និងរឹងមូលធនមនុស្សនិងការសម្របសម្រួលគោលនយោបាយជាពិសេសថ្មីៗនេះរាជរដ្ឋាភិបាលទើបតែបានអនុម័តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ២០១៥-២០២៥ដែលក្នុងនោះវិស័យកសិ-ឧស្សាហកម្មគឺជាវិស័យ អាទិភាពដ៏សំខាន់មួយក្នុងវិស័យអាទិភាពដទៃទៀតរបស់គោលនយោបាយនេះ។

## III- ចក្ខុវិស័យ និងយុទ្ធសាស្ត្រក្នុងការជំរុញអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

### ក. ចក្ខុវិស័យ និងទិសដៅយុទ្ធសាស្ត្រ

គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ បានចែងយ៉ាងច្បាស់អំពីចក្ខុវិស័យរបស់រាជរដ្ឋាភិបាល គឺជំរុញកែប្រែនិងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មនៅកម្ពុជា ពីឧស្សាហកម្មអតិពលកម្មឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥ តាមរយៈការតភ្ជាប់ទៅនឹងខ្សែសង្វាក់តម្លៃសកល សមាហ-រណកម្មទៅក្នុងបណ្តាញផលិតកម្មតំបន់ និងការអភិវឌ្ឍកន្សោមផលិតកម្មប្រទាក់ក្រឡា ទន្ទឹមនឹងការពង្រីកភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាពឧស្សាហកម្មក្នុងស្រុក ហើយបន្តឈានទៅអភិវឌ្ឍឧស្សាហកម្មទំនើប ដែលផ្អែកជាសំខាន់លើមូលដ្ឋានបច្ចេកវិទ្យានិងចំណេះដឹង។ ការសម្រេចបាននូវចក្ខុវិស័យនេះ នឹងរួមចំណែកដល់ ការអភិវឌ្ឍសេដ្ឋកិច្ចជាតិការទ្រទ្រង់និងលើកកម្ពស់កំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាពនិងបរិយាប័ន ការបង្កើតការងារជូនពលករកម្ពុជាការបង្កើតតម្លៃបន្ថែមសម្រាប់សេដ្ឋកិច្ចជាតិ និងការបង្កើនប្រាក់ចំណូលសមស្របជូនប្រជាជនកម្ពុជា។

គោលបំណងនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ គឺផ្តល់នូវក្របខណ្ឌគោលនយោបាយ ក្របខណ្ឌសម្របសម្រួលការអនុវត្ត និងការរៀបចំយន្តការស្ថាប័ន សម្រាប់ជំរុញការអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា។ កម្មវត្ថុសំខាន់នៃគោលនយោបាយនេះ គឺការដោះស្រាយបញ្ហាប្រឈមជារចនាសម្ព័ន្ធ និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម ឱ្យស្របតាមសក្តានុពល ឧត្តមភាពប្រកួតប្រជែង និងសភាពការណ៍វិវត្តន៍នៃឧស្សាហកម្មកម្ពុជា។

ដើម្បីសម្រេចចក្ខុវិស័យ និងគោលបំណងខាងលើ រាជរដ្ឋាភិបាលកំណត់យកគោលដៅចម្បងបីគឺ÷

(ទី១) ការកែប្រែនិងពង្រីករចនាសម្ព័ន្ធឧស្សាហកម្មក្នុងសេដ្ឋកិច្ចជាតិ ដោយបង្កើនអនុបាតនៃវិស័យឧស្សាហកម្មក្នុង ផសស ឱ្យបាន៣០%នៅឆ្នាំ២០២៥ ពី២៤,១%នៃផសសនៅឆ្នាំ២០១៣។

(ទី២) ការបង្កើននិងពិពិធកម្មមុខទំនិញនាំចេញ ដោយបង្កើនការនាំចេញទំនិញកម្មន្តសាល (មិនមែនជាវាយនភ័ណ្ឌ) ឱ្យបាន១៥% នៃបរិមាណនាំចេញសរុបនៅឆ្នាំ២០២៥ ទន្ទឹមនឹងជំរុញការនាំចេញទំនិញកែច្នៃកសិកម្មឱ្យបាន១២% នៃបរិមាណនាំចេញសរុបនៅឆ្នាំ២០២៥។

(ទី៣) ការពង្រឹងយន្តការគ្រប់គ្រង និងការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ដោយជំរុញការចុះបញ្ជី ផ្លូវការនៃសហគ្រាសទាំងនោះ រួមទាំងសហគ្រាសធុនធំផងដែរ និងលើកកម្ពស់អភិបាលកិច្ចសាជីវកម្មតាមរយៈការកាន់បញ្ជីការគណនេយ្យនិងតារាងតុល្យការ។ ជាគោលដៅនៅឆ្នាំ២០២៥ សហគ្រាសធុនតូច៨០% និងមធ្យម៩៥% នឹងត្រូវបានចុះបញ្ជីជាផ្លូវការ ហើយសហគ្រាសធុនតូច៥០% និងមធ្យម៧០% នឹងមានបញ្ជីការគណនេយ្យ និងតារាងតុល្យការត្រឹមត្រូវ។

## ខ. អភិក្រមដើម្បីសម្រេចបាននិសដៅគោលនយោបាយ

គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥បានបង្ហាញច្បាស់ពីអភិក្រមនៃការអនុវត្តគឺ÷

(១) ធានានូវបរិយាកាសនិយ័តកម្មដែលមានលក្ខណៈអំណោយផល ផ្តល់នូវការគាំទ្រនិងការលើកទឹកចិត្តសមស្របសម្រាប់វិស័យអាទិភាព រួមទាំងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់បម្រើឲ្យសកម្មភាពកសិ-ឧស្សាហកម្ម សំដៅបង្កើតឲ្យបានកាន់តែច្រើននូវសហគ្រាសកសិ-ឧស្សាហកម្មការកែច្នៃកសិផល តម្រង់ទិសការអភិវឌ្ឍតំបន់កសិ-ឧស្សាហកម្មដើម្បីធានានូវភាពប្រមូលផ្តុំ និងការតភ្ជាប់ទៅនឹងសួនឧស្សាហកម្មនិងកន្សោមឧស្សាហកម្ម។

(២) តម្រង់ទិសលើការផ្លាស់ប្តូររចនាសម្ព័ន្ធសំខាន់ៗដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ពិសេសពាក់ព័ន្ធនឹងការបណ្តុះបណ្តាលជំនាញនិងការអប់រំបច្ចេកទេសការជំរុញនវានុវត្តន៍បច្ចេកវិទ្យា។

(៣) សម្រួលប្រព័ន្ធផ្គត់ផ្គង់វត្ថុធាតុដើម ឬធាតុចូលប្រកបដោយគុណភាព ស្ថិរភាព និងថ្លៃទាប សម្រាប់ផលិតកម្មកសិ-ឧស្សាហកម្ម។

(៤) ការគាំទ្របច្ចេកទេស ហិរញ្ញវត្ថុ និងការលើកទឹកចិត្តផ្សេងៗ ត្រូវអនុវត្តដោយផ្អែកលើសមិទ្ធកម្ម កម្មវត្ថុគោលនយោបាយច្បាស់លាស់ និងសកម្មភាពអនុវត្តជាក់ស្តែង ដូចជាការសម្រេចគោលដៅលើបរិមាណនាំចេញ ឬលទ្ធផលជាក់ស្តែងពីដំណើរការបង្កើតរោងចក្រឧស្សាហកម្មថ្មី។

(៥) យកចិត្តទុកដាក់លើការការពារបរិស្ថាន ដើម្បីបញ្ចៀសការបំពុលបរិស្ថាន ដោយសារកាកសំណល់ឧស្សាហកម្ម និងសារធាតុគីមីផ្សេងៗ។

## គ. គោលនយោបាយ និងស្ថាប័នជំរុញការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម

រហូតមកដល់ពេលបច្ចុប្បន្ននេះក្រសួង-ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធនឹងការជំរុញការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្មបានដាក់ចេញនូវគោលនយោបាយយុទ្ធសាស្ត្រផែនការសកម្មភាពនិងឯកសារគតិយុត្តពាក់ព័ន្ធសំខាន់ៗមួយចំនួនដូចខាងក្រោម÷

| ល.រ. | ឯកសារគោលនយោបាយ | កាលបរិច្ឆេទ | ស្ថាប័ននាំមុខ/<br>ទទួលខុសត្រូវ |
|---|---|---|---|
| ១ | គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥ | ខែមីនា ឆ្នាំ២០១៥ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួង-ស្ថាប័នពាក់ព័ន្ធ |
| **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | | | |
| ២ | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨ | | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៣ | ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ | | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **ផ្នែកដំណាំ** | | | |
| ៤ | យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជាឆ្នាំ២០១១-២០២០ | ខែសីហា ឆ្នាំ២០១១ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង- ស្ថាប័នពាក់ព័ន្ធ |
| ៥ | គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ | ខែសីហា ឆ្នាំ២០១០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង- ស្ថាប័នពាក់ព័ន្ធ |
| ៦ | ផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ | ខែមេសា ឆ្នាំ២០១១ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង- ស្ថាប័នពាក់ព័ន្ធ |
| ៧ | ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ | ខែឧសភា ឆ្នាំ២០០៨ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៨ | អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា | ខែកុម្ភៈ ឆ្នាំ២០១១ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង- ស្ថាប័នពាក់ព័ន្ធ |
| **ផ្នែកជលផល** | | | |
| ៩ | ក្របខណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផល ឆ្នាំ២០១០-២០១៩ | ខែកក្កដា ឆ្នាំ២០១១ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង- ស្ថាប័នពាក់ព័ន្ធ |
| **ផ្នែកព្រៃឈើ** | | | |
| ១០ | កម្មវិធីព្រៃឈើជាតិ ឆ្នាំ២០១០-២០២៩ | ខែតុលា ឆ្នាំ២០១០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង- ស្ថាប័នពាក់ព័ន្ធ |
| **គោលនយោបាយ និងយុទ្ធសាស្ត្រគាំទ្រវិស័យកសិ-ឧស្សាហកម្ម** | | | |
| ១១ | ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជា- ណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ១១១ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជា- ណាចក្រកម្ពុជា | ឆ្នាំ២០០៣ឆ្នាំ / ២០០៥ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ១២ | យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០១៤-២០១៨ | ខែមករា ឆ្នាំ២០១៤ | ក្រសួងពាណិជ្ជកម្ម និងក្រសួង- ស្ថាប័នពាក់ព័ន្ធ |

| | | | |
|---|---|---|---|
| ១៣ | សេចក្ដីព្រាងក្របខណ្ឌគោលនយោបាយលើកទឹកចិត្តសហគ្រាសធុនតូច និងមធ្យម | ខែមេសា ឆ្នាំ២០១៥ | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួង-ស្ថាប័នពាក់ព័ន្ធ |
| ១៤ | មូលនិធិធានាឥណទាន | ខែធ្នូ ឆ្នាំ២០១០ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ១៥ | មូលនិធិទ្រទ្រង់ និងអភិវឌ្ឍន៍វិស័យកសិកម្ម | ខែមិថុនា ឆ្នាំ២០០៩ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ១៦ | ផែនការកាត់បន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅ តំបន់ផ្គត់ផ្គង់នានាដែលបានទទួលប្រភពអគ្គិសនីពីហេដ្ឋារចនាសម្ព័ន្ធអភិវឌ្ឍ | ខែមករា ឆ្នាំ២០១៥ | ក្រសួងរ៉ែ និងថាមពល |
| ១៧ (?) | សេចក្ដីសម្រេចស្ដីពី ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល និងដោះស្រាយវិវាទ នៅតំបន់គម្រោងវិនិយោគអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ នៅក្នុងដែនជម្រកសត្វព្រៃស្នួលក្នុងភូមិសា-ស្ត្រខេត្តក្រចេះ និងខេត្តមណ្ឌលគីរី | ខែមករា ឆ្នាំ២០១១ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ១៨ | អនុក្រឹត្យលេខ ១៩៩ អនក្រ.បក ស្ដីពីការបង្កើតធនាគារអភិវឌ្ឍន៍ជនបទ | ខែមិថុនា ឆ្នាំ២០១៤ | ធនាគារអភិវឌ្ឍន៍ជនបទ |
| ១៩ | ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗទៀត | | |

# ផ្នែកទី ២:
# ផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥

## IV- ផែនការសកម្មភាព

### *១.១ វិធានការជំរុញការទាក់ទាញវិនិយោគ*

ដើម្បីចូលរួមចំណែកក្នុងការអនុវត្តវិធានការពាក់ព័ន្ធនឹងការជំរុញការទាក់ទាញវិនិយោគ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវអនុវត្តសកម្មភាពសំខាន់ៗចំនួន៨ដូចខាងក្រោម÷

១.១. រៀបចំនិងផ្សព្វផ្សាយសៀវភៅមគ្គុទេសស្តីពីការវិនិយោគក្នុងវិស័យកសិ-ឧស្សាហកម្ម

១.២. កំណត់ និងសិក្សាវាយតម្លៃតំបន់ដាំដុះ និងកែច្នៃផលិតផលកសិកម្មសំខាន់ៗ (ស្រូវ ពោត ដំឡូងមី អំពៅ សណ្តែកសៀង ស្វាយចន្ទី ម្រេច ស្វាយ ចេក បន្លែ ផ្លែឈើ និងដំណាំដែលមានសក្តានុពលផ្សេងទៀត)

១.៣. រៀបចំយន្តការសម្របសម្រួលនិងគាំទ្រក្នុងការបង្កើត និងដំណើរការតំបន់កសិ-ឧស្សាហកម្ម (ស្រូវ ពោត ដំឡូងមី អំពៅ ស្វាយ ចេក សណ្តែកសៀង ស្វាយចន្ទី ម្រេច បន្លែ ផ្លែឈើ និងដំណាំដែលមានសក្តានុពលផ្សេងទៀត) សម្រាប់ប្រមូលផ្តុំផលិតកម្ម កែច្នៃ វេចខ្ចប់ សម្រាប់ទីផ្សារក្នុងស្រុកនិងនាំចេញ

១.៤. សិក្សា វិភាគ និងវាយតម្លៃតំបន់សក្តានុពលនៃផលិតកម្មកៅស៊ូធម្មជាតិនៅកម្ពុជា *(តំបន់១÷ កំពង់ចាម ត្បូងឃ្មុំ ក្រចេះ ព្រៃវែង និងស្វាយរៀង តំបន់២÷ មណ្ឌលគីរី ស្ទឹងត្រែង និងរតនគីរី តំបន់៣÷ កំពង់ធំ ព្រះវិហារ ឧត្តរមានជ័យ សៀមរាប និងបន្ទាយមានជ័យ តំបន់៤÷ បាត់ដំបង ប៉ៃលិន ពោធិ៍សាត់ កោះកុង ព្រះសីហនុ កំពត កំពង់ស្ពឺ)*

១.៥. សិក្សា វិភាគ និងវាយតម្លៃតំបន់សក្តានុពលអភិវឌ្ឍន៍វារីវប្បកម្ម (*តំបន់ជុំវិញបឹងទន្លេសាប តំបន់តាមដងទន្លេមេគង្គ និងតំបន់ឆ្នេរសមុទ្រ*) សំដៅផ្គត់ផ្គង់វត្ថុធាតុដើមដល់ឧស្សាហកម្មកែច្នៃជលផល និងជំរុញការនាំចេញ

១.៦. កំណត់និងសិក្សាវាយតម្លៃតំបន់សក្តានុពលផលិតកម្មសត្វនៅកម្ពុជា (*តំបន់ចិញ្ចឹមសត្វតាមប្រភេទ កន្លែងផលិតចំណីសត្វ បសុឱសថ សត្តឃាតដ្ឋាន និងកន្លែងកែច្នៃផលិតផលសត្វ*)

១.៧. រៀបចំកែលម្អនីតិវិធីស្នើសុំបង្កើតមូលដ្ឋានកែច្នៃឈើ សម្រាប់ប្រើប្រាស់ក្នុងស្រុកនិងនាំចេញ សំដៅលើកទឹកចិត្តដល់ការអភិវឌ្ឍការកែច្នៃផលិតផលព្រៃឈើពីប្រភពស្របច្បាប់របស់វិស័យឯកជន

១.៨. រៀបចំកែលម្អនីតិវិធីស្នើសុំផ្តល់អាជ្ញាប័ណ្ណសម្រាប់ការនាំចូល នាំចេញដើម្បីបញ្ជាក់ភាពស្របច្បាប់របស់ផលអនុផលព្រៃឈើ

### *១.២ វិធានការពង្រីកនិងទំនើបកម្មសហគ្រាសកសិកម្មធុនតូចនិងមធ្យម*

ដើម្បីចូលរួមចំណែកក្នុងការអនុវត្តវិធានការពាក់ព័ន្ធនឹងការពង្រីកនិងទំនើបកម្មសហគ្រាសកសិកម្មធុនតូចនិងមធ្យម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវអនុវត្តសកម្មភាពសំខាន់ៗចំនួន៣២ ដូចខាងក្រោម÷

២.១. ស្រាវជ្រាវ អភិវឌ្ឍ និងផ្សព្វផ្សាយពូជដំណាំដែលមានផលិតភាពខ្ពស់ ធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ និងឆ្លើយតបទីផ្សារ ជាសក្តានុពលសម្រាប់ផលិតជាវត្ថុធាតុដើមបម្រើឱ្យវិស័យកសិ-ឧស្សាហកម្ម

២.២. បង្កើតនិងជំរុញការអនុវត្តបច្ចេកវិទ្យាសមស្រប និងការប្រើប្រាស់ធាតុចូលប្រកបដោយគុណភាពក្នុងផលិតកម្មកសិកម្ម រួមទាំងការអនុវត្តកសិកម្មល្អ(GoodAgricultural Practice-GAP) ការអនុវត្តល្អក្នុងវិស័យចិញ្ចឹមសត្វ (Good Animal Husbandry Practice-GAHP) ការអនុវត្តវារីវប្បកម្មល្អ (GoodAquaculture Practice GAP) ការអនុវត្តអនាម័យល្អ (Good Hygiene Practice -GHP) ការអនុវត្តផលិតល្អ (Good Manufacturing Practice-GMP) ក្នុងខ្សែសង្វាក់ផលិតកម្មកសិកម្ម ដែលមានសក្តានុពលសម្រាប់ការកែច្នៃ និងនាំចេញ

២.៣. ពង្រីកនិងពង្រឹងសមត្ថភាពសហគមន៍កសិកម្មឱ្យក្លាយជាសហគ្រាសសេដ្ឋកិច្ចជនបទ សម្រាប់ការកសាងភាពជាដៃគូជាមួយផ្នែកឯកជនតាមរយៈផលិតកម្មកសិកម្មតាមកិច្ចសន្យា

២.៤. ទំនើបកម្មមន្ទីរពិសោធន៍វិភាគគុណភាព និងសុវត្ថិភាពធាតុចូលនិងផលិតផលកសិកម្មដោយអនុលោមតាមបទដ្ឋានបច្ចេកទេសមានការទទួលស្គាល់ជាសកល

២.៥. កសាងមន្ទីរពិសោធន៍បង្អែកអនាម័យនិងភូតគាមអនាម័យ (SPS Reference Laboratory) ដោយបំពាក់នូវឧបករណ៍និងបច្ចេកវិទ្យាទំនើបទាន់សម័យដើម្បីសម្រួលការត្រួតពិនិត្យនិងចេញវិញ្ញាបនបត្រអនាម័យនិងភូតគាមអនាម័យ

២.៦. រៀបចំបង្កើតសាខាត្រួតពិនិត្យអនាម័យសត្វ និងភូតគាមអនាម័យប្រចាំតំបន់ និងបង្កើតស្នាក់ការត្រួតពិនិត្យអនាម័យសត្វនិងភូតគាមអនាម័យនៅតាមច្រកទ្វារព្រំដែនអន្តរជាតិ និងធ្វើប្រតិបត្តិការ ដើម្បីសម្រួលការនាំចេញផលិតផលដែលមានដើមកំណើតពីសត្វនិងដំណាំកសិកម្ម បង្ការទប់ស្កាត់ការរាតត្បាតជំងឺសត្វនិងការរាតត្បាត សមាសភាពចង្រៃជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងភូតគាមអនាម័យ

២.៧. អភិវឌ្ឍស្វ័យប្រវត្តិកម្មប្រព័ន្ធវិញ្ញាបនកម្មភូតគាមអនាម័យដើម្បីសម្រួលការធ្វើពាណិជ្ជកម្មនិងនាំចេញផលិតផលកសិកម្ម

២.៨. លើកកម្ពស់ការយល់ដឹងអំពីលិខិតបទដ្ឋានច្បាប់និងនីតិវិធីស្នើសុំការត្រួតពិនិត្យនិងផ្តល់វិញ្ញាបនបត្រអនាម័យនិងភូតគាមអនាម័យ

២.៩. ពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនិងបំពាក់បរិក្ខារគាំទ្រ ការសិក្សាស្រាវជ្រាវ អភិវឌ្ឍន៍ និងផ្ទេរបច្ចេកវិទ្យាតាមបណ្តាកសិដ្ឋាននិងស្ថានីយស្រាវជ្រាវកសិកម្ម

២.១០. ពង្រឹងនិងពង្រីកមូលដ្ឋានការសិក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍លើមុខដំណាំសេដ្ឋកិច្ចសំខាន់ៗសម្រាប់បម្រើឱ្យឧស្សាហកម្មកែច្នៃនិងការនាំចេញ (ស្រូវ ពោត សណ្តែកសៀង ម្រេច ដំឡូងមី ចេក ស្វាយ ស្វាយចន្ទី និងបន្លែ)

២.១១. ជំរុញការអនុវត្តអនុក្រឹត្យស្តីពីផលិតកម្មតាមកិច្ចសន្យាក្នុងគោលដៅពង្រឹងការភ្ជាប់ទំនាក់ទំនងនិងភាពជាដៃគូរវាងគ្រួសារកសិករខ្នាតតូច ក្រុមកសិករ សហគមន៍កសិកម្ម ជាមួយ ក្រុមហ៊ុនវិនិយោគខ្នាតមធ្យមនិងធំ

២.១២. បណ្តុះបណ្តាលជំនាញ និងធនធានមនុស្សក្នុងផ្នែកអភិវឌ្ឍកៅស៊ូដល់មន្ត្រីជំនាញ (Training of Trainers-TOT)

២.១៣. រៀបចំចងក្រងឯកសារបច្ចេកទេស និងផ្តល់ការបណ្តុះបណ្តាលដល់កសិករ/សហគមន៍កៅស៊ូគ្រួសារ អំពីការចៀរជ័រកៅស៊ូ ការកែច្នៃ ការស្តុកទុក និងបច្ចេកទេសក្រោយពេលប្រមូលផលផលិតផលកៅស៊ូដ៏ទៃទៀត

២.១៤. ពង្រឹងនិងពង្រីកសហគមន៍កៅស៊ូគ្រួសារ ឱ្យមានលក្ខណៈប្រមូលផ្តុំផលិតកម្ម សម្រាប់ផ្គត់ផ្គង់វត្ថុធាតុដើមដល់រោងចក្រកែច្នៃកៅស៊ូឯកជន

២.១៥. រៀបចំបង្កើតអនុស្ថានីយស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេស និងនវានុវត្តន៍ផ្នែកអភិវឌ្ឍកៅស៊ូ ដើម្បីបង្កើនគុណភាព និងផលិតភាពកៅស៊ូ

២.១៦. ពង្រឹងហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់បរិក្ខាគាំទ្រការសិក្សាស្រាវជ្រាវ អភិវឌ្ឍន៍ និងផ្ទេរបច្ចេកវិទ្យាដល់កសិករចិញ្ចឹមសត្វ

២.១៧. សម្របសម្រួលនិងគាំទ្រក្នុងការបង្កើត និងដំណើរការតំបន់ប្រមូលផ្តុំកន្លែងចិញ្ចឹមសត្វ កសិដ្ឋានចិញ្ចឹមសត្វ កន្លែងផលិតចំណីសត្វ បសុឃាតដ្ឋានកន្លែងកែច្នៃនិងវេចខ្ចប់សាច់ និងផលិតផលសត្វដែលមានលក្ខណៈទំនើប សម្រាប់លើកកម្ពស់លក្ខខណ្ឌអនាម័យ គុណភាពនិងសុវត្ថិភាពធានាដល់សុខភាពសាធារណៈ

២.១៨. ចងក្រងនិងពង្រឹងសមត្ថភាពសហគមន៍អភិវឌ្ឍន៍ការចិញ្ចឹមសត្វ ចំណីសត្វ និងកែច្នៃផលិតផលសាច់

២.១៩. ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍វិភាគរោគវិនិច្ឆ័យជំងឺសត្វ គុណភាពនិងសុវត្ថិភាពសាច់ និងផលិតផលសត្វ គុណភាពចំណីសត្វ និងបសុឃាតដ្ឋានអនុលោមតាមបទដ្ឋាន ដែលទទួលស្គាល់ជាសកល

២.២០. បង្កើតមន្ទីរពិសោធន៍អនាម័យសត្វតំបន់ (Regional SPS Laboratory) ដោយបំពាក់នូវឧបករណ៍និងបច្ចេកវិទ្យាសមស្របដើម្បីសម្រួលដល់ការវិភាគរោគវិនិច្ឆ័យជំងឺសត្វ គុណភាព និងសុវត្ថិភាពសាច់ និងផលិតផលសត្វ

២.២១. សិក្សា វាយតម្លៃសក្តានុពលនៃការផ្គត់ផ្គង់ និងតម្រូវការប្រើប្រាស់ផល អនុផលព្រៃឈើ និងកំណត់ចំនួនមូលដ្ឋានកែច្នៃផល អនុផលព្រៃឈើ និងអត្រាកែច្នៃផលិតផល សំដៅពង្រឹងការគ្រប់គ្រងមូលដ្ឋានកែច្នៃផល អនុផលព្រៃឈើ ប្រកបដោយប្រសិទ្ធភាព

២.២២. ស្រាវជ្រាវនិងអភិវឌ្ឍផលិតផលព្រៃឈើ និងបច្ចេកវិទ្យា ប្រកបដោយប្រសិទ្ធភាពខ្ពស់ កំណត់និយមន័យឱ្យបានច្បាស់លាស់នូវផលិតផលព្រៃឈើស្របច្បាប់ក្នុងប្រទេសកម្ពុជា

២.២៣. ស្រាវជ្រាវរកផលិតផលព្រៃឈើកែច្នៃដែលមានចរិតលក្ខណៈប្រពៃណីវប្បធម៌របស់សហគមន៍ ដើម្បីធ្វើការកែសម្រួលបច្ចេកទេសកែច្នៃផលិតផលផ្តល់នូវតម្លៃបន្ថែម

២.២៤. រៀបចំវគ្គបណ្តុះបណ្តាលដល់ផលិតករកែច្នៃផល អនុផលព្រៃឈើ ពិសេសសហគមន៍មូលដ្ឋាននូវចំណេះដឹង និងបច្ចេកទេសកែច្នៃ ព្រមទាំងតម្រូវការផលិតផលនៅលើទីផ្សារ

២.២៥. រៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីជំនាញ និងអ្នកពាក់ព័ន្ធលើការងារស្រាវជ្រាវ និងអភិវឌ្ឍផលិតផលព្រៃឈើ និងរៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលការណ៍ណែនាំបច្ចេកទេស ចំណេះដឹងអំពីលក្ខណៈវិនិច្ឆ័យ និងសូចនាករតាមស្តង់ដារជាតិ (Criteria and Indicator-C&I) ដើម្បីឈានទៅទទួលបានការបញ្ជាក់វិញ្ញាបនបត្រព្រៃឈើ

២.២៦. ជំរុញផ្សព្វផ្សាយព័ត៌មានទីផ្សារ និងបច្ចេកវិទ្យាកែច្នៃផល អនុផលព្រៃឈើ ដល់សហគមន៍មូលដ្ឋានវិស័យឯកជន និងអ្នកពាក់ព័ន្ធ និងព័ត៌មានទីផ្សារ

២.២៧. បង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍ផលិតផលម្ហូបអាហារនិងបណ្តុះបណ្តាល (មជ្ឈមណ្ឌលនេះនឹងច្នៃបង្កើតផលិតផលម្ហូបអាហារថ្មី ធ្វើការវិភាគគុណភាពម្ហូបអាហារ និងជាកន្លែងផ្តល់ការបណ្តុះបណ្តាល ដល់សហគ្រិននិងអ្នកដែលចង់បង្កើតមុខរបរថ្មីដែលពាក់ព័ន្ធនឹងការផលិតអាហារ)

២.២៨. បង្កើនការអនុវត្តជាក់ស្តែងនៅក្នុងស្ថានីយ មន្ទីរពិសោធន៍ និងការចូលរួមក្នុងការស្រាវជ្រាវ ដើម្បីពង្រឹងគុណភាពបណ្តុះបណ្តាលផ្នែកកសិកម្មនិងកសិ-ឧស្សាហកម្ម

២.២៩. សិក្សា ស្រាវជ្រាវ ដើម្បីកំណត់បញ្ហានិងរកដំណោះស្រាយ ដល់សហគ្រាសផលិតម្ហូបអាហារ និងផ្នែកពាក់ព័ន្ធនឹងការអភិវឌ្ឍកសិ-ឧស្សាហកម្ម

២.៣០. ផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសបណ្តុះបណ្តាលនិងត្រួតពិនិត្យសកម្មភាពនៃការកែច្នៃផលិតផលកសិកម្មនិងកសិ-ម្ហូបអាហារជូនដល់កសិករសហគមន៍កសិកម្មអ្នកប្រមូលទិញផលិតផលកសិកម្មឬឈ្មួញកណ្តាលនិងសហគ្រាសកែច្នៃស្របតាមបទដ្ឋានបច្ចេកទេសរបស់ប្រព័ន្ធសុវត្ថិភាពចំណីអាហារដូចជា÷គោលការណ៍GHP, GMP, HACCP សម្រាប់ផលិតផលកសិកម្មនិងកសិ-ម្ហូបអាហារ សំដៅចូលរួមដើម្បីបង្កើនតម្លៃបន្ថែមនិងការរក្សាទុកបានយូរ ក្នុងការប្រកួតប្រជែងដណ្តើមទីផ្សារនិងបង្កើនគុណភាពផ្នែកអាហារូបត្ថម្ភ

២.៣១. ពង្រឹងសមត្ថភាពវិភាគលើគុណភាពសុវត្ថភាពផលិតផលកសិកម្មក្នុងមន្ទីរពិសោធន៍ សិក្សាស្រាវជ្រាវអំពីនីតិវិធីនិងវិធីសាស្ត្រទំនើបសម្រាប់វិភាគគុណភាពសុវត្ថិភាពផលិតផលកសិកម្មនិងស្បៀងអាហារ និងបណ្តុះបណ្តាលបច្ចេកទេសវិភាគគុណភាពសុវត្ថិភាពក្នុងមន្ទីរពិសោធន៍ ដូចជា Mycotoxin, Salmonella, E.coli, GMO,....។ល។

២.៣២. ពង្រឹងនិងពង្រីកការអនុវត្តការងារបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីបង្កើនសមត្ថភាពធនធានមនុស្សផ្នែកជំនាញកសិកម្មនិងកសិ-ឧស្សាហកម្ម

## ១.៣ វិធានការពាក់ព័ន្ធនឹងការកែលម្អបរិស្ថាននិយ័តកម្ម

ដើម្បីចូលរួមចំណែកក្នុងការអនុវត្តវិធានការពាក់ព័ន្ធនឹងការកែលម្អបរិស្ថាននិយ័តកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវអនុវត្តសកម្មភាពសំខាន់ៗចំនួន១៥ ដូចខាងក្រោម÷

៣.១. ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជ

៣.២. ជំរុញរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីសហគមន៍កសិកម្ម

៣.៣. ជំរុញរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការការពារុក្ខជាតិនិងភូត គាមអនាម័យ

៣.៤. រៀបចំនិងលើកកម្ពស់ស្តង់ដារូបនីយកម្មដំណាំកសិកម្មនិងការវាយតម្លៃការទទួលស្គាល់អនុលោមភាព

៣.៥. រៀបចំគោលនយោបាយនិងឯកសារគតិយុត្តស្តីពីប្រតិបត្តិការនិងការគ្រប់គ្រងមន្ទីរពិសោធន៍កសិកម្មជាតិ

៣.៦. រៀបចំផែនការយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់ការអភិវឌ្ឍផលិតកម្មដំណាំ

៣.៧. បន្តរៀបចំបង្កើតច្បាប់ស្តីពីកៅស៊ូនិងលិខិតបទដ្ឋានក្រោមច្បាប់

៣.៨. ជំរុញការបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ និងលិខិតបទដ្ឋានក្រោមច្បាប់

៣.៩. រៀបចំផែនការយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់អភិវឌ្ឍន៍ផលិតកម្មសត្វនិងសុខភាពសត្វ

៣.១០. រៀបចំកែសម្រួលនិងធ្វើវិសោធនកម្មច្បាប់ស្តីពីជលផល
៣.១១. រៀបចំស្តង់ដារផល ផលិតផលជលផល ដែលមានសក្តានុពលនាំចេញ
៣.១២. រៀបចំកែលម្អនិងធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋាន និងបច្ចេកទេសស្រប ទៅតាមសភាពការណ៍រីកចម្រើនរបស់ប្រទេស និងនិន្នាការវិវត្តន៍របស់ទីផ្សារ ព្រមទាំងសិទ្ធិចូលរួមរបស់ប្រជាជនមូលដ្ឋានផ្នែកឯកជនក្នុងការអភិវឌ្ឍអាជីវកម្មកែច្នៃនិងធ្វើពាណិជ្ជកម្មផលិតផលព្រៃឈើ
៣.១៣. រៀបចំនិងអនុវត្តនូវប្រព័ន្ធផ្តល់វិញ្ញាបនបត្របញ្ជាក់លើផលិតផលព្រៃឈើសំខាន់ៗ
៣.១៤. បង្កើតផែនការយុទ្ធសាស្ត្រនិងគោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងអភិវឌ្ឍន៍ផលិតផលព្រៃឈើកែច្នៃក្នុងស្រុកនិងពង្រឹងទីផ្សារ
៣.១៥. រៀបចំនិងអនុវត្តលិខិតបទដ្ឋានគតិយុត្តសម្រាប់ជំរុញការអនុវត្តអនុក្រឹត្យស្តីពី ផលិតកម្មកសិកម្មតាមកិច្ចសន្យា

### ១.៤ វិធានការសម្របសម្រួលគោលនយោបាយ

ដើម្បីចូលរួមចំណែកក្នុងការអនុវត្តវិធានការពាក់ព័ន្ធនឹងការសម្របសម្រួលគោលនយោបាយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវអនុវត្តសកម្មភាពសំខាន់ៗចំនួន៦ ដូចខាងក្រោម÷

៤.១. កំណត់យន្តការសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យកសិ-ឧស្សាហកម្ម
៤.២. បង្កើនការចរចាតម្រូវការអនុវត្តវិធានអនាម័យសត្វ និងភូតគាមអនាម័យ ដើម្បីបើកច្រកនាំចេញផលិតផលកសិកម្ម ទៅកាន់ទីផ្សារអន្តរជាតិ
៤.៣. រៀបចំនិងប្រតិបត្តិយន្តការ "**ច្រកចេញចូលតែមួយ**" លើរាល់ការផ្តល់សេវាសាធារណៈក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
៤.៤. ពង្រីកនិងពង្រឹងទំនាក់ទំនងរវាងគ្រឹះស្ថានបណ្តុះបណ្តាលជាមួយក្រុមហ៊ុននិងសហគ្រាសកសិ-ឧស្សាហកម្ម ដើម្បីបង្កើនសមត្ថភាពជំនាញនិងឱកាសការងាររបស់និស្សិត
៤.៥. សិក្សាគោលនយោបាយសម្រាប់ជំរុញការអភិវឌ្ឍកសិកម្ម និងកសិ-ឧស្សាហកម្ម
៤.៦. បង្កើតវេទិកាច្នៃប្រឌិតបង្ហាញស្នាដៃថ្មី និងគម្រោងកសិធុរកិច្ច ដើម្បីបង្កើនទេព្យកោសល្យដែលមាន និងបង្កើតកម្លាំងចលករឲ្យខិតខំបង្កើតនវានុវត្តន៍

## V- គម្រោងថវិកាសម្រាប់អនុវត្តផែនការសកម្មភាព

ដើម្បីអនុវត្តផែនការសកម្មភាព សម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវការថវិកាសរុបចំនួនប្រមាណ**១១៥,៧០លាន**ដុល្លារអាមេរិកសម្រាប់អនុវត្តក្នុងរយៈពេល១០ឆ្នាំ (២០១៥-២០២៥) ដែលក្នុងនោះ ÷

- ថវិកាចំនួន ១,៥០ លានដុល្លារអាមេរិក គ្រោងសម្រាប់អនុវត្តបណ្តាសកម្មភាពគាំទ្រដល់វិធានការជំរុញការទាក់ទាញវិនិយោគ

- ថវិកាចំនួន ១០៨,៥០ លានដុល្លារអាមេរិក គ្រោងសម្រាប់អនុវត្តបណ្តាសកម្មភាពគាំទ្រដល់ការពង្រីកនិងទំនើបកម្មសហគ្រាសកសិកម្មធុនតូចនិងមធ្យម
- ថវិកាចំនួន ៣,៣០ លានដុល្លារអាមេរិក គ្រោងសម្រាប់អនុវត្តបណ្តាសកម្មភាពគាំទ្រដល់ការកែលម្អបរិស្ថាននិយ័តកម្ម (ការរៀបចំលិខិតបទដ្ឋាន) និង
- ថវិកាចំនួន ២,៤០ លានដុល្លារអាមេរិក គ្រោងសម្រាប់អនុវត្តបណ្តាសកម្មភាពគាំទ្រដល់ការការសម្របសម្រួលគោលនយោបាយ។

បណ្តាអង្គភាពជំនាញ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ពន្ធ័នឹងការអនុវត្តផែនការសកម្មភាពនេះ ត្រូវរៀបចំផែនការថវិកាលម្អិត ដើម្បីដាក់បញ្ចូលទៅក្នុងក្របខណ្ឌថវិកាកម្មវិធី ចំពោះសកម្មភាពដែលមានចរិតជាចំណាយចរន្ត និងត្រូវត្រៀមរៀបចំនិងដាក់បញ្ចូលនូវបណ្តាសកម្មភាព (ឬគម្រោងលម្អិត) ដែលជាចំណាយមូលធន ទៅក្នុងកម្មវិធីវិនិយោគសាធារណៈ ដើម្បីទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ ពីរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍន៍នានា។

ក្រុមការងាររៀបចំផែនការថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសមាសភាពសំខាន់មកពីនាយកដ្ឋានផែនការនិងស្ថិតិ និងនាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ ត្រូវរៀបចំចាត់ចែងនិងសម្របសម្រួលក្នុងការងាររៀបចំផែនការសកម្មភាពនិងថវិកា សំដៅធ្វើយ៉ាងណាឲ្យសកម្មភាពទាំងឡាយក្នុងផែនការនេះ អាចអនុវត្តបានប្រកបដោយប្រសិទ្ធភាពខ្ពស់។

## VI- យន្តការអនុវត្តការតាមដាននិងវាយតម្លៃ

### ១. យន្តការអនុវត្តផែនការសកម្មភាព

ការអនុវត្តផែនការសកម្មភាពនេះ ទាមទារនូវយន្តការដឹកនាំនិងគ្រប់គ្រងច្បាស់លាស់ និងមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព។ ការចូលរួមអនុវត្តពីគ្រប់អង្គភាពជំនាញក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាចំណុចគន្លឹះចាំបាច់ ដើម្បីចូលរួមសម្រេចបាននូវគោលដៅនៃការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម។

ក្រុមការងារសម្រាប់ចូលរួមអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ដែលបានបង្កើតឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសេចក្តីសម្រេចលេខ២២៦ សសរ.កសក ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១៥ នឹងដើរតួនាទីយ៉ាងសំខាន់ ក្នុងការសម្របសម្រួល និងគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវ សំដៅជំរុញការអនុវត្តនូវរាល់សកម្មភាពដែលបានកំណត់ដាក់ឱ្យអនុវត្តក្នុងផែនការនេះ។ ក្រុមការងារនេះ នឹងត្រូវរៀបចំឱ្យមានកិច្ចប្រជុំពិគ្រោះយោបល់ជាប្រចាំ (ប្រជុំត្រីមាស ឆមាស និងប្រចាំឆ្នាំ) ដើម្បីក្តាប់ឱ្យបាននូវការវិវឌ្ឍវីកចម្រើននៃការអនុវត្តផែនការសកម្មភាព និងចាត់វិធានការនានា ដើម្បីដោះស្រាយចំណុចរាំងស្ទះទាំងឡាយដែលអង្គភាពជំនាញក្រោមឱវាទជួបប្រទះ។

អង្គភាពជំនាញក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានភារកិច្ចអនុវត្តផែនការសកម្មភាពនេះ ត្រូវរៀបចំយន្តការអនុវត្តជាក់ស្តែងតាមផ្នែករបស់ខ្លួន ដើម្បីធានានូវការអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។

## ២.	ការតាមដាននិងវាយតម្លៃ

- នាយកដ្ឋានផែនការនិងស្ថិតិមានភារកិច្ចទទួលពិនិត្យតាមដាននិងវាយតម្លៃលើការអនុវត្តរាល់សកម្មភាពនានាដូចមានចែងក្នុងផែនការសកម្មភាពនេះ។
- បណ្តានាយកដ្ឋានអង្គភាពជំនាញនានាដែលពាក់ពន្ធ័ក្នុងការអនុវត្តផែនការសកម្មភាពនេះត្រូវរាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានផែនការនិងស្ថិតិ) ពីលទ្ធផលសម្រេចបានឲ្យបានទៀងទាត់តាមរយៈការផ្តល់របាយការណ៍ប្រចាំត្រីមាស ឆមាសនិងប្រចាំឆ្នាំ។
- របាយការណ៍អនុវត្តនិងសមិទ្ធផលសម្រេចបានក្នុងការអនុវត្តនេះនឹងត្រូវរៀបចំបូកសរុបដោយនាយកដ្ឋានផែនការនិងស្ថិតិ
- នាយកដ្ឋានផែនការនិងស្ថិតិ និងក្រុមការងារអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជានឹងចុះឬមានវិធានការឲ្យចុះត្រួតពិនិត្យ វាយតម្លៃដល់មូលដ្ឋានអនុវត្តគម្រោង។
- ផ្អែកលើរបាយការណ៍បូកសរុបវាយតម្លៃខាងលើនេះក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ (ក្រុមការងារសម្រាប់ចូលរួមអនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា) ត្រូវកោះប្រជុំត្រួតពិនិត្យវាយតម្លៃ សន្និដ្ឋានផ្តល់អនុសាសន៍ជំរុញណែនាំអនុវត្ត មុននឹងក្រសួងរាយការណ៍ជូនទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីមានមូលដ្ឋានរាយការណ៍ជូនរាជរដ្ឋាភិបាលកម្ពុជា។

# VII-	សេចក្តីសន្និដ្ឋាន

ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទបានប្តេជ្ញាចិត្តខ្ពស់ក្នុងការជំរុញការអនុវត្តគោលនយោបាយ អភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា សំដៅចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជានិងបង្កើនល្បឿននៃការជំរុញកំណើនសេដ្ឋកិច្ចជាតិ។ ដោយសារកម្ពុជាមានសក្តានុពលផ្នែកផលិតកម្មកសិកម្មដែលជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍផ្នែកកសិ-ឧស្សាហកម្ម គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ពិតជាមានសារសំខាន់បំផុតក្នុងការជួយជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។ ផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយដែលបានរៀបចំកសាងឡើងនេះ នឹងអាចអនុវត្តបានជោគជ័យគឺអាស្រ័យដោយការតាំងចិត្តពុះពាររួមនឹងការជួយឧបត្ថម្ភគាំទ្រទាំងផ្នែកស្មារតី សម្ភារនិងថវិកាពីរាជរដ្ឋាភិបាលកម្ពុជាក៏ដូចជាមានការចូលរួមចំណែកពីបណ្តាដៃគូអភិវឌ្ឍន៍ ដើម្បីអនុវត្តនូវបណ្តាសកម្មភាពនិងវិធានការគោលនយោបាយទាំងឡាយដូចដែលបានរៀបរាប់ក្នុងឯកសារផែនការសកម្មភាពនេះ។

កត្តាអវិជ្ជមាននិងឧបសគ្គនានាដែលនឹងអាចរាំងស្ទះក្នុងការជំរុញផលិតកម្មដំណាំកសិកម្មគឺកត្តាគ្រោះថ្នាក់ពីធម្មជាតិដែលនឹងអាចកើតមានដូចជាគ្រោះទឹកជំនន់ភាពរាំងស្ងួតកត្តាបំផ្លិចបំផ្លាញពីសត្វល្អិតចង្រៃ។ល។ ប៉ុន្តែទោះជាយ៉ាងណាក្តីឧបសគ្គទាំងនេះនឹងអាចកាត់បន្ថយបានតាមរយៈការតាំងចិត្តនិងការខិតខំជម្នះ ដើម្បីទទួលបានជោគជ័យក្នុងការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្មនេះ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងជំរុញការអនុវត្តផែនការសកម្មភាពនេះ ដើម្បីចូលរួមចំណែកជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឲ្យមានប្រសិទ្ធភាពខ្ពស់ និងមានជំនឿជឿជាក់ថាផែនការសកម្មភាពដែលបានរៀបចំនេះ ពិតជានឹងអាចអនុវត្តទៅបានប្រកបដោយជោគជ័យ។

# ផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥
# របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឯកតា÷ លានដុល្លារអាមេរិក

| ល.រ | វិធានការគោលនយោបាយ/ ផែនការសកម្មភាព | សូចនាករ | រយៈពេលខ្លី | រយៈពេលមធ្យម | រយៈពេលវែង | តម្រូវការថវិកា | អង្គភាពទទួលខុសត្រូវអនុវត្ត |
|---|---|---|---|---|---|---|---|
| | | | ២០១៥ | ២០១៦-២០១៨ | ២០១៩-២០២៥ | | |
| **១)** | **ការជំរុញការទាក់ទាញវិនិយោគ** | | | | | | |
| ១.១ | រៀបចំនិងផ្សព្វផ្សាយសៀវភៅមគ្គុទេសស្តីពីការវិនិយោគក្នុងវិស័យកសិ-ឧស្សាហកម្ម | សៀវភៅមគ្គុទេស (ភាសាខ្មែរនិងអង់គ្លេស) ត្រូវបានរៀបចំ និងផ្សព្វផ្សាយ | x | x | x | 0,១0 | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ១.២ | កំណត់ និងសិក្សាវាយតម្លៃតំបន់ដាំដុះ និងកែច្នៃផលិតផលកសិកម្មសំខាន់ៗ (ស្រូវ ពោត ដំឡូងមី អំពៅ សណ្តែកសៀង ស្វាយចន្ទី ម្រេច ស្វាយ ចេក បន្លែ ផ្លែឈើ និងដំណាំដែលមានសក្តានុពលផ្សេងទៀត) | របាយការណ៍និងផែនទីកំណត់តំបន់ដាំដុះ និងកែច្នៃផលិតផលកសិកម្មត្រូវបានផ្សព្វផ្សាយ | x | x | | 0,២0 | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកសិកម្ម, នាយកដ្ឋានកសិ-ឧស្សាហកម្ម) |
| ១.៣ | រៀបចំយន្តការសម្របសម្រួលនិងគាំទ្រ ក្នុងការបង្កើត និងដំណើរការតំបន់កសិ-ឧស្សាហកម្ម (ស្រូវ ពោត ដំឡូងមី អំពៅ ស្វាយ ចេក សណ្តែកសៀង ស្វាយចន្ទី ម្រេច បន្លែ ផ្លែឈើ និងដំណាំដែលមានសក្តានុពលផ្សេងទៀត) សម្រាប់ប្រមូលផ្តុំផលិតកម្ម កែច្នៃ វេចខ្ចប់ សម្រាប់ទីផ្សារក្នុងស្រុក និងនាំចេញ | តំបន់កសិ-ឧស្សាហកម្មគំរូ៥កន្លែងត្រូវបានបង្កើតនិងដំណើរការ | x | x | x | 0,២0 | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(អគ្គនាយកដ្ឋានកសិកម្ម,នាយកដ្ឋានផែនការ និងស្ថិតិ, នាយកដ្ឋានកសិ-ឧស្សាហកម្ម,វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា) |
| ១.៤ | សិក្សា វិភាគ និងវាយតម្លៃតំបន់សក្តានុពលនៃផលិតកម្មកៅស៊ូធម្មជាតិនៅកម្ពុជា *(តំបន់១÷ កំពង់ចាម ត្បូងឃ្មុំ ក្រចេះ ព្រៃវែង និងស្វាយរៀង តំបន់២÷ មណ្ឌលគិរី ស្ទឹងត្រែង និងរតនគិរី តំបន់៣÷ កំពង់ធំ ព្រះវិហារ* | របាយការណ៍សិក្សាវាយតម្លៃតំបន់សក្តានុពលនៃផលិតកម្មកៅស៊ូធម្មជាតិទាំង៤ ត្រូវបានផ្សព្វផ្សាយ | | x | x | 0,២0 | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកៅស៊ូ) |

| | | | | | | |
|---|---|---|---|---|---|---|
| | *ឧត្តរមានជ័យ សៀមរាប និងបន្ទាយមានជ័យ តំបន់៤÷ បាត់ដំបង ប៉ៃលិន ពោធិ៍សាត់ កោះកុង ព្រះសីហនុ កំពត កំពង់ស្ពឺ)* | | | | | |
| ១.៥ | សិក្សា វិភាគ និងវាយតម្លៃតំបន់សក្តានុពលអភិវឌ្ឍន៍វារីវប្បកម្ម ( *តំបន់ជុំវិញបឹងទន្លេសាប តំបន់តាមដងទន្លេមេគង្គ និងតំបន់ឆ្នេរសមុទ្រ*) សំដៅផ្គត់ផ្គង់វត្ថុធាតុដើមដល់ឧស្សាហកម្មកែច្នៃជលផល និងជំរុញការនាំចេញ | របាយការណ៍សិក្សាវាយតម្លៃតំបន់សក្តានុពលនៃតំបន់អភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានផ្សព្វផ្សាយ | x | x | | ០,៣០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលជលផល) |
| ១.៦ | កំណត់និងសិក្សាវាយតម្លៃតំបន់សក្តានុពលផលិតកម្មសត្វនៅកម្ពុជា (*តំបន់ចិញ្ចឹមសត្វតាមប្រភេទ កន្លែងផលិតចំណីសត្វ បសុឱសថ សត្តឃាតដ្ឋាន និងកន្លែងកែច្នៃផលិតផលសត្វ*) | តំបន់សក្តានុពលផលិតកម្មសត្វត្រូវបានកំណត់ និងសិក្សាវាយតម្លៃ | x | x | x | ០,៣០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល) |
| ១.៧ | រៀបចំកែលម្អនីតិវិធីស្នើសុំបង្កើតមូលដ្ឋានកែច្នៃឈើសម្រាប់ប្រើប្រាស់ក្នុងស្រុកនិងនាំចេញ សំដៅលើកទឹកចិត្តដល់ការអភិវឌ្ឍការកែច្នៃផលិតផលព្រៃឈើពីប្រភពស្របច្បាប់របស់វិស័យឯកជន | នីតិវិធីស្នើសុំបង្កើតមូលដ្ឋានកែច្នៃឈើត្រូវបានកែលម្អនិងអនុវត្ត | x | x | | ០,១០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលព្រៃឈើ) |
| ១.៨ | រៀបចំកែលម្អនីតិវិធីស្នើសុំផ្តល់អាជ្ញាប័ណ្ណសម្រាប់ការនាំចូលនាំចេញដើម្បីបញ្ជាក់ភាពស្របច្បាប់របស់ផល អនុផលព្រៃឈើ | នីតិវិធីស្នើសុំអាជ្ញាប័ណ្ណនាំចូលនាំចេញផលិតផលព្រៃឈើត្រូវបានកែលម្អនិងអនុវត្ត | x | x | | ០,១០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលព្រៃឈើ) |
| | | | | | **សរុបថវិកា** | **១,៥** | |
| ២) | **ការពង្រីកនិងទំនើបកម្មសហគ្រាសកសិកម្មធុនតូចនិងមធ្យម** | | | | | |
| ២.១ | ស្រាវជ្រាវ អភិវឌ្ឍនិងផ្សព្វផ្សាយពូជដំណាំដែលមានផលិតភាពខ្ពស់ ធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ និងឆ្លើយតបទីផ្សារជាសក្តានុពលសម្រាប់ផលិតជាវត្ថុធាតុដើមបម្រើឱ្យវិស័យកសិ-ឧស្សាហកម្ម | ពូជដំណាំស្រូវ ពោត សណ្តែកសៀង ស្វាយ ចេក ដែលមានផលិតភាពខ្ពស់ ត្រូវបានអភិវឌ្ឍនិងផ្សព្វផ្សាយ | x | x | x | ១០,០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា,អគ្គនាយកដ្ឋានកសិកម្ម) |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២.២ | បង្កើត និង ជំរុញការអនុវត្តបច្ចេកវិទ្យាសមស្រប និងការប្រើប្រាស់ធាតុចូលប្រកបដោយគុណភាពក្នុងផលិតកម្មកសិកម្ម រួមទាំងការអនុវត្តកសិកម្មល្អ (GoodAgricultural Practice-GAP) ការអនុវត្តល្អក្នុងវិស័យចិញ្ចឹមសត្វ (Good Animal Husbandry Practice-GAHP) ការអនុវត្តវារីវប្បកម្មល្អ (GoodAquaculture Practice-GAP) ការអនុវត្តអនាម័យ ល្អ (Good Hygiene Practice -GHP) ការអនុវត្តផលិតល្អ (Good Manufacturing Practice-GMP) ក្នុងខ្សែសង្វាក់ ផលិតកម្មកសិកម្ម ដែលមានសក្តានុពលសម្រាប់ការកែច្នៃនិងនាំចេញ | - កំណើននៃការប្រើប្រាស់បង្កុំបច្ចេកវិទ្យានិងធាតុចូលប្រកបដោយគុណភាពក្នុងផលិតកម្មកសិកម្ម ត្រូវបានអនុវត្តយ៉ាងតិច ១០%ក្នុង១ឆ្នាំ<br>- គោលការណ៍ណែនាំសម្រាប់ការអនុវត្តល្អក្នុងការចិញ្ចឹមសត្វនៅតាមកសិដ្ឋានយ៉ាងតិចចំនួន១០០ ត្រូវបានអនុវត្ត<br>- កសិដ្ឋានវារីវប្បកម្ម និងកន្លែងកែច្នៃ យ៉ាងតិច១០០កន្លែង/ឆ្នាំ អនុវត្តតាមគោលការណ៍ណែនាំ | x | x | x | ១៥,០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(អគ្គនាយកដ្ឋានកសិកម្ម, រដ្ឋបាលជលផល, នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល,វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា) |
| ២.៣ | ពង្រីកនិងពង្រឹងសមត្ថភាពសហគមន៍កសិកម្មឱ្យក្លាយជាសហគ្រាសសេដ្ឋកិច្ចជនបទ សម្រាប់ការកសាងភាពជាដៃគូជាមួយផ្នែកឯកជនតាមរយៈផលិតកម្មកសិកម្មតាមកិច្ចសន្យា | សហគមន៍កសិកម្មយ៉ាងតិច ១០០/ឆ្នាំ ត្រូវពង្រីកនិងពង្រឹងសមត្ថភាព | x | x | x | ៥,០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកសិកម្ម, នាយកដ្ឋានកសិ-ឧស្សាហកម្ម) |
| ២.៤ | ទំនើបកម្មមន្ទីរពិសោធន៍វិភាគគុណភាព និងសុវត្ថិភាពធាតុចូលនិងផលិតផលកសិកម្មដោយអនុលោមតាមបទដ្ឋានបច្ចេកទេសមានការទទួលស្គាល់ជាសកល | មន្ទីរពិសោធន៍ជាតិកសិកម្មត្រូវមានសមត្ថភាពផ្តល់សេវាពិសោធន៍វិភាគពេញលេញទ្រទ្រង់ដល់ដំណើការផលិតកម្ម កែច្នៃ និងនាំចេញ | x | x | x | ៤,០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកសិកម្ម) |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ផលិតផលកសិកម្ម | | | | | |
| ២.៥ | កសាងមន្ទីរពិសោធន៍បង្អែកអនាម័យនិងភូតគាមអនាម័យ(SPS Reference Laboratory) ដោយបំពាក់នូវឧបករណ៍និងបច្ចេកវិទ្យាទំនើបទាន់សម័យដើម្បីសម្រួលការត្រួតពិនិត្យនិងចេញវិញ្ញាបនបត្រអនាម័យនិងភូតគាមអនាម័យ | សមត្ថភាពបង្ការទប់ស្កាត់ការឆ្លងរាលដាលសមាសភាពចង្រៃជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យត្រូវបានពង្រឹង | x | x | x | ២,០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ (អគ្គនាយកដ្ឋានកសិកម្ម) |
| ២.៦ | រៀបចំបង្កើតសាខាត្រួតពិនិត្យអនាម័យសត្វនិងភូតគាមអនាម័យប្រចាំតំបន់និងបង្កើតស្នាក់ការត្រួតពិនិត្យអនាម័យសត្វនិងភូតគាមអនាម័យនៅតាមច្រកទ្វារព្រំដែនអន្តរជាតិ និងធ្វើប្រតិបត្តិការ ដើម្បីសម្រួលការនាំចេញផលិតផលដែលមានដើមកំណើតពីសត្វនិងដំណាំកសិកម្មបង្ការទប់ស្កាត់ការរាតត្បាតជំងឺសត្វនិងការរាតត្បាតសមាសភាពចង្រៃជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វនិងភូតគាមអនាម័យ | ការនាំចេញផលិតផលកសិកម្មត្រូវបានសម្រួល និងសមត្ថភាពក្នុងបង្ការទប់ស្កាត់ការរាតត្បាតជំងឺសត្វនិងការរាតត្បាតសមាសភាពចង្រៃជាកម្មនៃកាត្រួតពិនិត្យភូតគាមអនាម័យត្រូវបានពង្រឹង | x | x | x | ៥,០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ (អគ្គនាយកដ្ឋានកសិកម្ម, នាយកដ្ឋានផលិកម្មនិងបុសព្យាបាល) |
| ២.៧ | អភិវឌ្ឍស្វ័យប្រវត្តិកម្មប្រព័ន្ធវិញ្ញាបនកម្មភូតគាមអនាម័យដើម្បីសម្រួលការធ្វើពាណិជ្ជកម្មនិងនាំចេញផលិតផលកសិកម្ម | ប្រព័ន្ធស្វ័យប្រវត្តិកម្មសម្រាប់ការចេញវិញ្ញាបនបត្រភូតគាមអនាម័យត្រូវបានដាក់ឱ្យដំណើរការ | x | x | x | ៣,០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ (អគ្គនាយកដ្ឋានកសិកម្ម) |
| ២.៨ | លើកកម្ពស់ការយល់ដឹងអំពីលិខិតបទដ្ឋានច្បាប់និងនីតិវិធីស្នើសុំការត្រួតពិនិត្យនិងផ្ដល់វិញ្ញាបនបត្រអនាម័យនិងភូតគាមអនាម័យ | លិខិតបទដ្ឋានច្បាប់និងនីតិវិធីត្រូវបានផ្សព្វផ្សាយ និងពាណិជ្ជកម្មផលិតផលកសិកម្មត្រូវបានជំរុញ | x | x | x | ១,០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ (អគ្គនាយកដ្ឋានកសិកម្ម) |
| ២.៩ | ពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនិងបំពាក់បរិក្ខារគាំទ្រការសិក្សាស្រាវជ្រាវ អភិវឌ្ឍន៍ និងផ្ទេរបច្ចេកវិទ្យាតាមបណ្ដាកសិដ្ឋាន និងស្ថានីយស្រាវជ្រាវកសិកម្ម | បណ្ដាកសិដ្ឋាននិងស្ថានីយស្រាវជ្រាវកសិកម្មត្រូវបានបង្កើនសមត្ថភាព សម្រាប់ការសិក្សាស្រាវជ្រាវ អភិវឌ្ឍន៍ និងផ្ទេរបច្ចេកវិទ្យា | x | x | x | ៧,០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ (អគ្គនាយកដ្ឋានកសិកម្ម) |
| ២.១០ | ពង្រឹងនិងពង្រីកមូលដ្ឋានការសិក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍ | ផែនការមេស្ដីពីការសិក្សាស្រាវជ្រាវ | x | x | x | ១,០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | លើមុខដំណាំសេដ្ឋកិច្ចសំខាន់ៗសម្រាប់បម្រើឱ្យឧស្សាហកម្មកែច្នៃនិងការនាំចេញ (ស្រូវ ពោត សណ្តែកសៀង ម្រេច ដំឡូងមី ចេក ស្វាយ ស្វាយចន្ទី និងបន្លែ) | វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ក្នុងអនុវិស័យដំណាំត្រូវបានកសាង និងអនុវត្តប្រកបដោយប្រសិទ្ធភាព | | | | | និងនេសាទ (អគ្គនាយកដ្ឋានកសិកម្ម, វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ) |
| ២.១១ | ជំរុញការអនុវត្តអនុក្រឹត្យស្តីពីផលិតកម្មតាមកិច្ចសន្យាក្នុងគោលដៅពង្រឹងការភ្ជាប់ទំនាក់ទំនងនិងភាពជាដៃគូរវាងគ្រួសារកសិករខ្នាតតូច ក្រុមកសិករ សហគមន៍កសិកម្ម ជាមួយក្រុមហ៊ុនវិនិយោគខ្នាតមធ្យមនិងធំ | អនុក្រឹត្យស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យាត្រូវបានជំរុញឱ្យអនុវត្តពេញលេញនៅក្នុងទូទាំងប្រទេស | x | x | x | ២,៥០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ(នាយកដ្ឋានកសិ-ឧស្សាហកម្ម,អគ្គនាយកដ្ឋានកសិកម្ម,នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល, រដ្ឋបាល ជលផល,អង្គភាពពាក់ព័ន្ធ) |
| ២.១២ | បណ្តុះបណ្តាលជំនាញ និងធនធានមនុស្សក្នុងផ្នែកអភិវឌ្ឍកៅស៊ូដល់មន្ត្រីជំនាញ (Training of Trainers-TOT) | វគ្គបណ្តុះបណ្តាលចំនួន២០ ត្រូវបានរៀបចំ | | x | x | ១,០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ (អគ្គនាយកដ្ឋានកៅស៊ូ) |
| ២.១៣ | រៀបចំចងក្រងឯកសារបច្ចេកទេស និងផ្តល់ការបណ្តុះបណ្តាលដល់កសិករ/ សហគមន៍កៅស៊ូគ្រួសារ អំពីការចៀរជ័រកៅស៊ូ ការកែច្នៃ ការស្តុកទុក និងបច្ចេកទេសក្រោយពេលប្រមូលផលផលិតផលកៅស៊ូដ៏ទៃទៀត | ឯកសារបច្ចេកទេសត្រូវបានរៀបចំ និងវគ្គបណ្តុះបណ្តាលយ៉ាងតិច ១០វគ្គ/ ឆ្នាំ ត្រូវបានរៀបចំ | x | x | x | ១,០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ (អគ្គនាយកដ្ឋានកៅស៊ូ) |
| ២.១៤ | ពង្រឹងនិងពង្រីកសហគមន៍កៅស៊ូគ្រួសារ ឱ្យមានលក្ខណៈប្រមូលផ្តុំផលិតកម្ម សម្រាប់ផ្គត់ផ្គង់វត្ថុធាតុដើមដល់រោងចក្រកែច្នៃកៅស៊ូឯកជន | សហគមន៍កៅស៊ូគ្រួសារចំនួន១០០ សហគមន៍នឹងត្រូវបានបង្កើត | x | x | x | ២,០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ (អគ្គនាយកដ្ឋានកៅស៊ូ) |
| ២.១៥ | រៀបចំបង្កើតអនុស្ថានីយស្រាវជ្រាវិទ្យាសាស្ត្របច្ចេកទេស និងនវានុវត្តន៍ផ្នែកអភិវឌ្ឍកៅស៊ូ ដើម្បីបង្កើនគុណភាពនិងផលិតភាពកៅស៊ូ | អនុស្ថានីយពិសោធន៍ស្រាវជ្រាវចំនួនយ៉ាងតិច៣ ត្រូវបានបង្កើត | | x | x | ៣,៥០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ (អគ្គនាយកដ្ឋានកៅស៊ូ) |
| ២.១៦ | ពង្រឹងហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់បរិក្ខាគាំទ្រការសិក្សាស្រាវជ្រាវអភិវឌ្ឍន៍និងផ្ទេរបច្ចេកវិទ្យាដល់កសិករចិញ្ចឹមសត្វ | ប្រព័ន្ធសិក្សាស្រាវជ្រាវ អភិវឌ្ឍន៍ និងផ្ទេរបច្ចេក | x | x | | ១,៥០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | វិទ្យាដល់កសិករចិញ្ចឹមសត្វត្រូវបានពង្រឹង | | | | | (នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល) |
| ២.១៧ | សម្របសម្រួលនិងគាំទ្រក្នុងការបង្កើត និងដំណើរការតំបន់ប្រមូលផ្តុំកន្លែងចិញ្ចឹមសត្វ កសិដ្ឋានចិញ្ចឹមសត្វកន្លែងផលិត ចំណីសត្វ បសុឱសថកន្លែងកែច្នៃនិងវេចខ្ចប់សាច់ និងផលិតផលសត្វដែលមានលក្ខណៈទំនើប សម្រាប់លើកកម្ពស់លក្ខខណ្ឌអនាម័យគុណភាព និងសុវត្ថិភាពធានាដល់សុខភាពសាធារណៈ | តំបន់ប្រមូលផ្តុំកន្លែងចិញ្ចឹមសត្វ កសិដ្ឋានចិញ្ចឹមសត្វ កន្លែងផលិតចំណីសត្វ បសុឱសថកន្លែងកែច្នៃ និងវេចខ្ចប់សាច់យ៉ាងតិច១០០ កន្លែងត្រូវបានបង្កើតនិង ដំណើរការ | x | x | x | ១,០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល) |
| ២.១៨ | ចងក្រងនិងពង្រឹងសមត្ថភាពសហគមន៍អភិវឌ្ឍន៍ការចិញ្ចឹមសត្វ ចំណីសត្វ និងកែច្នៃផលិតផលសាច់ | សហគមន៍យ៉ាងតិចចំនួន៣០ ត្រូវបានចងក្រង និងពង្រឹងសមត្ថភាព | x | x | x | ២,០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល) |
| ២.១៩ | ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍វិភាគរោគវិនិច្ឆ័យជំងឺសត្វ គុណភាពនិងសុវត្ថិភាពសាច់ និងផលិតផលសត្វ គុណភាពចំណីសត្វ និងបសុឱសថអនុលោមតាមបទដ្ឋានដែលទទួលស្គាល់ជាសកល | សមត្ថភាពមន្ទីរពិសោធន៍ ត្រូវបានពង្រឹង | x | x | x | ១០,០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល) |
| ២.២០ | បង្កើតមន្ទីរពិសោធន៍អនាម័យសត្វតំបន់ (Regional SPS Laboratory) ដោយបំពាក់នូវឧបករណ៍និងបច្ចេកវិទ្យាសមស្របដើម្បីសម្រួលដល់ការវិភាគរោគវិនិច្ឆ័យជំងឺសត្វ គុណភាព និងសុវត្ថិភាពសាច់ និងផលិតផលសត្វ | មន្ទីរពិសោធន៍បង្អែកយ៉ាងតិច៤ តាមតំបន់ត្រូវបានបង្កើត | x | x | x | ៥,០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល) |
| ២.២១ | សិក្សា វាយតម្លៃសក្តានុពលនៃការផ្គត់ផ្គង់ និងតម្រូវការប្រើប្រាស់ផល អនុផលព្រៃឈើ និងកំណត់ចំនួនមូលដ្ឋានកែច្នៃផល អនុផលព្រៃឈើ និងអត្រាកែច្នៃផលិតផល សំដៅពង្រឹងការគ្រប់គ្រងមូលដ្ឋានកែច្នៃផល អនុផលព្រៃឈើប្រកបដោយប្រសិទ្ធភាព | របាយការណ៍សិក្សាវាយតម្លៃមូលដ្ឋានកែច្នៃ និងអត្រាកែច្នៃ ត្រូវបានចងក្រង និងអនុវត្ត | | x | x | ០,៣០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលព្រៃឈើ) |
| ២.២២ | ស្រាវជ្រាវនិងអភិវឌ្ឍផលិតផលព្រៃឈើ និងបច្ចេកវិទ្យា | ផលិតផលព្រៃឈើនិងបច្ចេកវិទ្យា | | x | x | ៥,០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ប្រកបដោយប្រសិទ្ធភាពខ្ពស់ កំណត់និយមន័យឲ្យបានច្បាស់លាស់នូវផលិតផលព្រៃឈើស្របច្បាប់ក្នុងប្រទេសកម្ពុជា | កែច្នៃថ្មីយ៉ាងតិចចំនួន២មុខត្រូវបានបង្កើតឡើងក្នុង០១ឆ្នាំ | | | | | និងនេសាទ (រដ្ឋបាលព្រៃឈើ) |
| ២.២៣ | ស្រាវជ្រាវរកផលិតផលព្រៃឈើកែច្នៃដែលមានចរិតលក្ខណៈប្រពៃណីវប្បធម៌របស់សហគមន៍ដើម្បីធ្វើការកែសម្រួលបច្ចេកទេសកែច្នៃផលិតផលផ្តល់នូវតម្លៃបន្ថែម | ផលិតផលព្រៃឈើកែច្នៃយ៉ាងតិចចំនួន២មុខ ត្រូវបានបង្កើតឡើងក្នុង០១ឆ្នាំ | | x | x | ០,២០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលព្រៃឈើ) |
| ២.២៤ | រៀបចំវគ្គបណ្តុះបណ្តាលដល់ផលិតករកែច្នៃផល អនុផលព្រៃឈើ ពិសេសសហគមន៍មូលដ្ឋាននូវចំណេះដឹង និងបច្ចេកទេសកែច្នៃ ព្រមទាំងតម្រូវការផលិតផលនៅលើទីផ្សារ | ផលិតករកែច្នៃផល អនុផលព្រៃឈើ និងសហគមន៍មូលដ្ឋាន យ៉ាងតិច៥០០នាក់/ឆ្នាំ ទទួលការបណ្តុះបណ្តាល | | x | x | ០,៥០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលព្រៃឈើ) |
| ២.២៥ | រៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីជំនាញនិងអ្នកពាក់ព័ន្ធលើការងារស្រាវជ្រាវ និងអភិវឌ្ឍផលិតផលព្រៃឈើ និងរៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលការណ៍ណែនាំបច្ចេកទេស ចំណេះដឹងអំពីលក្ខណៈវិនិច្ឆ័យ និងសូចនាករតាមស្តង់ដារជាតិ (Criteria and Indicator-C&I) ដើម្បីឈានទៅទទួលបានការបញ្ជាក់វិញ្ញាបនបត្រព្រៃឈើ | អ្នកពាក់ព័ន្ធនឹងវិស័យព្រៃឈើយ៉ាងតិច២០០នាក់/ឆ្នាំ ទទួលបានការបំពាក់បំប៉ន | | x | x | ០,៥០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលព្រៃឈើ) |
| ២.២៦ | ជំរុញផ្សព្វផ្សាយព័ត៌មានទីផ្សារ និងបច្ចេកវិទ្យាកែច្នៃផល អនុផលព្រៃឈើ ដល់សហគមន៍មូលដ្ឋានវិស័យឯកជន និងអ្នកពាក់ព័ន្ធ និងព័ត៌មានទីផ្សារ | សហគមន៍មូលដ្ឋានវិស័យឯកជន និងអ្នកពាក់ព័ន្ធ ទទួលបានព័ត៌មានទីផ្សារ និងបច្ចេកវិទ្យាកែច្នៃថ្មី | x | x | x | ០,៥០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលព្រៃឈើ) |
| ២.២៧ | បង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍ផលិតផលម្ហូបអាហារនិងបណ្តុះបណ្តាល(មជ្ឈមណ្ឌលនេះនឹងច្នៃបង្កើតផលិតផលម្ហូបអាហារថ្មី ធ្វើការវិភាគគុណភាពម្ហូបអាហារ និងជាកន្លែងផ្តល់ការបណ្តុះបណ្តាលដល់សហគ្រិននិងអ្នកដែលចង់បង្កើតមុខរបរថ្មីដែលពាក់ព័ន្ធនឹងការផលិតអាហារ) | ផលិតផលថ្មីយ៉ាងតិចចំនួន២មុខ/ឆ្នាំត្រូវ បានបង្កើត និងសហគ្រិនយ៉ាងតិចចំនួន ១០០នាក់ ត្រូវបាន ទទួលការបណ្តុះបណ្តាលជំនាញ អនុវត្តជាក់ស្តែង | | x | x | ៦,០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (សាកលវិទ្យាល័យភូមិន្ទកសិកម្ម, សាលាជាតិកសិកម្មព្រែកលៀប, សាលាជាតិកសិកម្មកំពង់ចាម) |
| ២.២៨ | បង្កើនការអនុវត្តជាក់ស្តែងនៅក្នុងស្ថានីយ មន្ទីរពិសោធន៍ | មន្ទីរពិសោធន៍យ៉ាងតិចចំនួន១៥ | | x | x | ៦,០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | និងការចូលរួមក្នុងការស្រាវជ្រាវ ដើម្បីពង្រឹងគុណភាពបណ្តុះបណ្តាលផ្នែកកសិកម្មនិងកសិ-ឧស្សហកម្ម | ត្រូវបានអនុវត្តពង្រឹងសមត្ថភាព | | | | | និងនេសាទ (សាកលវិទ្យាល័យភូមិន្ទកសិកម្ម, សាលាជាតិកសិកម្មព្រែកលៀប, សាលាជាតិកសិកម្មកំពង់ចាម) |
| ២.២៩ | សិក្សា ស្រាវជ្រាវ ដើម្បីកំណត់បញ្ហានិងរកដំណោះស្រាយដល់សហគ្រាសផលិតម្ហូបអាហារ និងផ្នែកពាក់ព័ន្ធនឹងការអភិវឌ្ឍកសិ-ឧស្សាហកម្ម | គម្រោងស្រាវជ្រាវចំនួន៧ ត្រូវបានអនុវត្តក្នុង១ឆ្នាំ | | x | x | ៣,០០ | (សាកលវិទ្យាល័យភូមិន្ទកសិកម្ម, សាលាជាតិកសិកម្មព្រែកលៀប, សាលាជាតិកសិកម្មកំពង់ចាម) |
| ២.៣០ | ផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសបណ្តុះបណ្តាលនិងត្រួតពិនិត្យសកម្មភាពនៃការកែច្នៃផលិតផលកសិកម្មនិងកសិ-ម្ហូបអាហារជូនដល់កសិករសហគមន៍កសិកម្មអ្នកប្រមូលទិញផលិតផលកសិកម្មឬឈ្មួញកណ្តាលនិងសហគ្រាសកែច្នៃស្របតាមបទដ្ឋានបច្ចេកទេសរបស់ប្រព័ន្ធសុវត្ថិភាពចំណីអាហារដូចជា÷គោលការណ៍GHP, GMP, HACCP សម្រាប់ផលិតផលកសិកម្មនិងកសិ-ម្ហូបអាហារសំដៅចូលរួមដើម្បីបង្កើនតម្លៃបន្ថែមនិងការរក្សាទុកបានយូរក្នុងការប្រកួតប្រជែងដណ្តើមទីផ្សារនិងបង្កើនគុណភាពផ្នែកអាហារូបត្ថម្ភ | វគ្គផ្សព្វផ្សាយបណ្តុះបណ្តាលយ៉ាងតិច២០វគ្គ/ឆ្នាំ ត្រូវបានរៀបចំ | x | x | x | 1,00 | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានកសិ-ឧស្សាហកម្ម) |
| ២.៣១ | ពង្រឹងសមត្ថភាពវិភាគលើគុណភាពសុវត្ថិភាពផលិតផលកសិកម្មក្នុងមន្ទីរពិសោធន៍ សិក្សាស្រាវជ្រាវអំពីនីតិវិធីនិងវិធីសាស្រ្តទំនើបសម្រាប់វិភាគគុណភាពសុវត្ថិភាពផលិតផលកសិកម្មនិងស្បៀងអាហារ និងបណ្តុះបណ្តាលបច្ចេកទេសវិភាគគុណភាពសុវត្ថិភាពក្នុងមន្ទីរពិសោធន៍ដូចជាMycotoxin, Salmonella, E.coli, GMO,....។ល។ | មន្ទីរពិសោធន៍មានសមត្ថភាពវិភាគលើគុណភាពសុវត្ថភាពផលិតផលកសិកម្មនិងវគ្គបណ្តុះបណ្តាលបច្ចេកទេសវិភាគគុណភាពសុវត្ថិភាពក្នុងមន្ទីរពិសោធន៍ត្រូវបានរៀបចំ | x | x | x | ១,០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានកសិ-ឧស្សាហកម្ម) |
| ២.៣២ | ពង្រឹងនិងពង្រីកការអនុវត្តការងារបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីបង្កើនសមត្ថភាពធនធានមនុស្សផ្នែកជំនាញ | អ្នកជំនាញកសិកម្មនិងកសិ-ឧស្សាហកម្មយ៉ាងតិចចំនួន១៥០០ | | x | x | ២,០០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | កសិកម្មនិងកសិ-ឧស្សាហកម្ម | នាក់ត្រូវបានបញ្ចប់ការសិក្សាដោយជោគជ័យក្នុង០១ឆ្នាំ | | | | | (សាកលវិទ្យាល័យភូមិន្ទកសិកម្ម, សាលាជាតិកសិកម្មព្រែកលៀប, សាលាជាតិកសិកម្មកំពង់ចាម) |
| | | | | | **សរុបថវិកា** | **១០៨,៥០** | |
| **៣)** | **ការកែលម្អបរិស្ថាននិយ័តកម្ម (ការរៀបចំលិខិតបទដ្ឋាន)** | | | | | | |
| ៣.១ | ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជ | លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជត្រូវបានរៀបចំ | x | x | | ០,១០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកសិកម្ម) |
| ៣.២ | ជំរុញរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីសហគមន៍កសិកម្ម | លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីសហគមន៍កសិកម្មត្រូវបានរៀបចំ | x | x | | ០,១០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកសិកម្ម) |
| ៣.៣ | ជំរុញរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការការពារុក្ខជាតិនិងភូតគាមអនាម័យ | ច្បាប់ស្តីពីការការពាររុក្ខជាតិនិងភូតគាមអនាម័យត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់ | x | x | | ០,១០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកសិកម្ម) |
| ៣.៤ | រៀបចំនិងលើកកម្ពស់ស្តង់ដារូបនីយកម្មដំណាំកសិកម្មនិងការវាយតម្លៃការទទួលស្គាល់អនុលោមភាព | ស្តង់ដារដំណាំកសិកម្មចំនួន៣៣មុខត្រូវបានរៀបចំជាស្តង់ដារជាតិនិងប្រកាសឱ្យប្រើប្រាស់ | x | x | | ០,៤០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកសិកម្ម) |
| ៣.៥ | រៀបចំគោលនយោបាយនិងឯកសារគតិយុត្តស្តីពីប្រតិបត្តិការនិងការគ្រប់គ្រងមន្ទីរពិសោធន៍កសិកម្មជាតិ | ឯកសារគតិយុត្តស្តីពីប្រតិបត្តិការនិងការគ្រប់គ្រងមន្ទីរពិសោធន៍កសិកម្មជាតិ ត្រូវបានរៀបចំ | x | x | | ០,១០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកសិកម្ម) |
| ៣.៦ | រៀបចំផែនការយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់ការអភិវឌ្ឍផលិតកម្មដំណាំ | ផែនការយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់ការអភិវឌ្ឍផលិតកម្មដំណាំ | x | x | x | ០,១០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកសិកម្ម, នាយកដ្ឋាន |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ត្រូវបានរៀបចំនិងអនុវត្ត | | | | | ផែនការ និងស្ថិតិ) |
| ៣.៧ | បន្តរៀបចំបង្កើតច្បាប់ស្តីពីកៅស៊ូនិងលិខិតបទដ្ឋានក្រោមច្បាប់ | ច្បាប់និងលិខិតបទដ្ឋានក្រោមច្បាប់ស្តីពីកៅស៊ូត្រូវបានបង្កើតនិងអនុវត្ត | x | x | | 0,១0 | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកៅស៊ូ) |
| ៣.៨ | ជំរុញការបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងលិខិតបទដ្ឋានក្រោមច្បាប់ | សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ និងលិខិតបទដ្ឋានក្រោមច្បាប់ ត្រូវបានបង្កើត | x | x | x | 0,១0 | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល) |
| ៣.៩ | រៀបចំផែនការយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់អភិវឌ្ឍន៍ផលិតកម្មសត្វនិងសុខភាពសត្វ | ផែនការយុទ្ធសាស្ត្រត្រូវបានបង្កើតនិងដាក់ឱ្យអនុវត្ត | x | x | x | 0,២0 | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល) |
| ៣.១0 | រៀបចំកែសម្រួលនិងធ្វើវិសោធនកម្មច្បាប់ស្តីពីជលផល | ច្បាប់ស្តីពីជលផលត្រូវបានរៀបចំកែសម្រួលនិងដាក់ឱ្យប្រើប្រាស់ | x | x | x | 0,១0 | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលជលផល) |
| ៣.១១ | រៀបចំស្តង់ដារផល ផលិតផលជលផល ដែលមានសក្តានុពលនាំចេញ | ស្តង់ដារផល ផលិតផលជលផល យ៉ាងតិច១0 ត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់ | x | x | x | 0,៤0 | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលជលផល) |
| ៣.១២ | រៀបចំកែលម្អនិងធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋាននិងបច្ចេកទេសស្របទៅតាមសភាពការណ៍រីកចម្រើនរបស់ប្រទេសនិងនិន្នាការវិវត្តន៍របស់ទីផ្សារព្រមទាំងសិទ្ធិចូលរួមរបស់ប្រជាជនមូលដ្ឋានផ្នែកឯកជនក្នុងការអភិវឌ្ឍអាជីវកម្មកែច្នៃនិងធ្វើពាណិជ្ជកម្មផលិតផលព្រៃឈើ | ច្បាប់ស្តីពីព្រៃឈើនិងលិខិតបទដ្ឋានបច្ចេកទេស ត្រូវបានរៀបចំកែលម្អ | x | x | x | 0,២0 | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលព្រៃឈើ) |
| ៣.១៣ | រៀបចំនិងអនុវត្តនូវប្រព័ន្ធផ្តល់វិញ្ញាបនបត្របញ្ជាក់លើ | ប្រព័ន្ធផ្តល់វិញ្ញាបនបត្រផលិតផល | | x | x | ១,00 | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ផលិតផលព្រៃឈើសំខាន់ៗ | ព្រៃឈើត្រូវបានរៀបចំនិងអនុវត្ត | | | | | និងនេសាទ (រដ្ឋបាលព្រៃឈើ) |
| ៣.១៤ | បង្កើតផែនការយុទ្ធសាស្ត្រនិងគោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងអភិវឌ្ឍន៍ផលិតផលព្រៃឈើកែច្នៃក្នុងស្រុកនិងពង្រីងទីផ្សារ | ផែនការយុទ្ធសាស្ត្រនិងគោលការណ៍ណែនាំត្រូវបានបង្កើត និង អនុវត្ត | | x | x | ០,២០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលព្រៃឈើ) |
| ៣.១៥ | រៀបចំនិងអនុវត្តលិខិតបទដ្ឋានគតិយុត្តសម្រាប់ជំរុញការអនុវត្តអនុក្រឹត្យស្តីពី ផលិតកម្មកសិកម្មតាមកិច្ចសន្យា | ឯកសារលិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | x | x | x | ០,១០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានកសិ-ឧស្សាហកម្ម, អង្គភាពពាក់ព័ន្ធ) |
| | | | | | **សរុបថវិកា** | **៣,៣០** | |
| ៤) | **ការសម្របសម្រួលគោលនយោបាយ** | | | | | | |
| ៤.១ | កំណត់យន្តការសម្របសម្រួលជាមួយក្រសួងស្ថាបនពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យកសិ-ឧស្សាហកម្ម | យន្តការសម្របសម្រួលក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យកសិ-ឧស្សាហកម្ម ត្រូវបានកំណត់ និងអនុវត្ត | x | x | x | ០,២០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួង ស្ថាបនពាក់ព័ន្ធ |
| ៤.២ | បង្កើនការចរចាតម្រូវការអនុវត្តវិធានអនាម័យសត្វ និងភូតគាមអនាម័យ ដើម្បីបើកច្រកនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិ | ឯកសារពិធីសារ អនុស្សរណៈយោគយល់គ្នា កិច្ចព្រមព្រៀង ពាក់ព័ន្ធការនាំចេញ ផលិតផល កសិ-ឧស្សាហកម្ម ត្រូវបានរៀបចំ និងអនុវត្ត | x | x | x | ០,៦០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកសិកម្ម, រដ្ឋបាលជលផល, នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល) |
| ៤.៣ | រៀបចំនិងប្រតិបត្តិយន្តការ “**ច្រកចេញចូលតែមួយ**” លើរាល់ការផ្តល់សេវាសាធារណៈក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | យន្តការ “**ច្រកចេញចូលតែមួយ**” ត្រូវ បានបង្កើតនិងអនុវត្តប្រកបដោយប្រសិទ្ធភាព | x | x | x | ០,១០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤.៤ | ពង្រីកនិងពង្រឹងទំនាក់ទំនងរវាងគ្រឹះស្ថានបណ្តុះបណ្តាលជាមួយក្រុមហ៊ុននិងសហគ្រាសកសិ-ឧស្សាហកម្មដើម្បីបង្កើនសមត្ថភាពជំនាញនិងឱកាសការងាររបស់និស្សិត | វេទិការវាងវិស័យឯកជនចំនួន២ក្នុងមួយឆ្នាំត្រូវបានរៀបចំ និងនិស្សិតចំនួន៣០នាក់ក្នុងមួយឆ្នាំមានឱកាសបង្កើតការងារ | | x | x | 0,៥0 | (សាកលវិទ្យាល័យភូមិន្ទកសិកម្ម, សាលាជាតិកសិកម្មព្រែកលៀប, សាលាជាតិកសិកម្មកំពង់ចាម) |
| ៤.៥ | សិក្សាគោលនយោបាយសម្រាប់ជំរុញការអភិវឌ្ឍកសិកម្មនិងកសិ-ឧស្សាហកម្ម | អត្ថបទគោលនយោបាយយ៉ាងតិចចំនួន៦ អត្ថបទវិទ្យាសាស្ត្រយ៉ាងតិចចំនួន២0 និងអត្ថបទផ្សព្វផ្សាយយ៉ាងតិចចំនួន១0 ត្រូវបានបង្កើត | | x | x | 0,៥0 | (សាកលវិទ្យាល័យភូមិន្ទកសិកម្ម, សាលាជាតិកសិកម្មព្រែកលៀប, សាលាជាតិកសិកម្មកំពង់ចាម) |
| ៤.៦ | បង្កើតវេទិកាថ្ងៃប្រទិតបង្ហាញស្នាដៃថ្មី និងគម្រោងកសិធុរកិច្ចដើម្បីបង្កើនទេព្យកោសល្យដែលមាន និងបង្កើតកម្លាំងចលករឲ្យខិតខំបង្កើតនវានុវត្តន៍ | វេទិកាប្រកួតប្រជែងចំនួន0១ក្នុង0១ឆ្នាំត្រូវបានរៀបចំ | | x | x | 0,៥0 | (សាកលវិទ្យាល័យភូមិន្ទកសិកម្ម, សាលាជាតិកសិកម្មព្រែកលៀប, សាលាជាតិកសិកម្មកំពង់ចាម) |
| **សរុបថវិកា** | | | | | | **២,៤0** | |
| **សរុបថវិការួម (លានដុល្លារអាមេរិក)** | | | | | | **១១៥,៧0** | |